វិទ្យាសាស្ត្រភាសា

# មូលដ្ឋាន

# នៃ

# ន័យកម្មវិទ្យាទូទៅ


ដោយ បណ្ឌិត ព្រុំ ម៉ល់

• អតីតសាស្ត្រាចារ្យភាសាវិទ្យា

- នៅមហាវិទ្យាល័យអក្សរសាស្ត្រ & មនុស្សសាស្ត្រ ភ្នំពេញ
- នៅមហាវិទ្យាល័យអក្សរសាស្ត្រ & មនុស្សសាស្ត្រ នៃក្រុង អាប៊ីទ្សង់ ប្រទេសកូដឺវ័រ

• សាស្ត្រាចារ្យបច្ចុប្បន្នខាងភាសាវិទ្យា

នៅរាជបណ្ឌិតសភាកម្ពុជា ភ្នំពេញ



រក្សាសិទ្ធិ



ចេញនៅខែមករា ឆ្នាំ២០០៣

# មាតិកា

## សញ្ញាណទូទៅ :

**I- សញ្ញាណទូទៅលើបញ្ញត្តិមូលដ្ឋាន :**


១- សូរស័ព្ទភាសា ឬ សូរស័ព្ទ (singne linguistique) ................................................... ទំព័រ ១

១.១- អ្វីហៅថា"សូរស័ព្ទភាសា" ? .................................................................................--- ១

១.២- លក្ខណៈនៃសូរស័ព្ទភាសា .....................................................................................--- ៤

១.៣- ប្រភេទន័យនៃសូរស័ព្ទភាសា ...................................................................................--- ៥

១.៣.១- ន័យកម្ម (signification) .....................................................................................--- ៥

១.៣.២- ន័យ (sens) ......................................................................................................--- ៥

១.៣.៣- យោប៉ោង (référence)...........................................................................................--- ៦

១.៣.៤- ន័យកម្មវិស័យ (dénotation)& ន័យអញ្ញថា (connotation)..............................--- ៦

១.៤- ព្រំដែន : តើសូរស័ព្ទភាសានៅត្រង់ណា ?...........................................................--- ៦

២- ពាក្យ (mot) .......................................................................................................--- ៧

៣- មូលស័ព្ទ (monème)& ស័ទ្ទតា (phonème) .........................................................--- ៧

៣.១- មូលស័ព្ទ ..........................................................................................................--- ៧

៣.២- ស័ទ្ទតា ............................................................................................................--- ៩

៤- វិចនស័ព្ទ (lexème) ..............................................................................................-- ១០

៥- រូបស័ព្ទ (morphème)& បណ្តាស័ព្ទ (allomorphes).................................................-- ១០

៦- បូរណស័ព្ទ (lexie)...................................................................................................-- ១២

៧- ការអនុវត្តតេស្តរកពាក្យសមាសបារាំង និង ការអនុវត្ត
បណ្តោះអាសន្នរកពាក្យសមាសខ្មែរ : .......................................................................-- ១៣

៧.១- ការអនុវត្ត លើ កន្សោមពាក្យបារាំង .........................................................................-- ១៣

៧.១.១- តេស្តជែក (test d'insertion) ................................................................................-- ១៣

៧.១.២- តេស្ត(តំណាក់)កត្តារួម (test de mise en facteur commun).......................-- ១៤

៧.១.៣- តេស្តកំណាត់ (test de répétition partielle) ....................................................-- ១៤

៧.១.៤- តេស្តតំណូរ (test de commutation) ..........................................................-- ១៥

៧.២- ការអនុវត្ត លើ កន្សោមពាក្យខ្មែរ ........................................................................-- ១៥

៧.២.១- តេស្តជែក .........................................................................................................-- ១៥

៧.២.២- តេស្ត (តំណាក់) កត្តារួម ..........................................................................-- ១៦

៧.២.៣- តេស្តកំណាត់ ...................................................................................................-- ១៦

៧.២.៤- តេស្តតំណូរ ......................................................................................................-- ១៧

**II- <u>សញ្ញាណទូទៅលើវិជ្ជាសន្ទាន/វិជ្ជាជិតខាងគ្នា</u> :**

១- ប្រវត្តិនៃបញ្ញត្តិមួយចំនួន និង វិជ្ជាពាក់ព័ន្ធ : ន័យកម្មវិទ្យា (sémiologie),
សញ្ញាវិទ្យា (sémiotique), និង ន័យវិទ្យា (sémantique) .......................................-- ១៧

២- រូបស័ព្ទវិទ្យា (morphologie) ..........................................................................-- ១៨

៣- វចនវិទ្យា/ស័ព្ទវិទ្យា (lexicologie) ..................................................................-- ១៨

៤- វាក្យស័ព្ទវិទ្យា ("lexistique") .............................................................................-- ១៩

៥- វចនាលេខនី (lexicographie) ..............................................................................-- ១៩

## គោលសំខាន់ៗ នៃ ន័យកម្មវិទ្យា :

១- ឯកតាក្នុងន័យ (unité de sens) ......................................................................-- ២០

១.១- ន័យតា (sème/component) និង វិភាគន័យតា
(analyse sémique/componentielle) ..........................................................-- ២០

១.២- អត្តន័យតា (sème identificateur/sui-sème) និង
ឋានន្តរន័យតា ( sème classificateur/classème) ........................................-- ២២

១.២.១- អត្តន័យតា (sui-sème) ..................................................................................-- ២២

១.២.២-ឋានន្តរន័យតា (classème) ..............................................................................-- ២២

១.៣- បូរណន័យតា (sémème) ...................................................................................-- ២៣

១.៤- អតិបូរណន័យតា (archi-sémème) ................................................................-- ២៤

១.៥- អតិវចនស័ព្ទ (archi-lexème) ........................................................................-- ២៤

២- ទំនាក់ទំនងរវាងន័យ (Relations sémantiques) ................................................-- ២៥

២.១- វិចារណកម្មទូទៅ .........................................................................................-- ២៥

២.២- សិក្សាលំអិតអំពីប្រភេទនីមួយៗនៃទំនាក់ទំនងរវាងន័យ .........................................-- ២៦

២.២.១- សទិសស័ព្ទ និង ពហុន័យ (homonyme & polysens) ....................................-- ២៦

២.២.១.១- សទិសស័ព្ទ ..............................................................................................-- ២៧

២.២.១.២- ពហុន័យ ....................................................................................................-- ២៨

២.២.២- វេវចនស័ព្ទ (synonyme)..................................................................................-- ២៩

២.២.៣- បដិស័ព្ទ (antonyme).......................................................................................-- ៣០

២.២.៤- អនុស័ព្ទ (hyponyme) & មហាស័ព្ទ (hyperonyme) ...................................-- ៣១

៣- បរិវេណ.ស័ព្ទ-ន័យសាស្ត្រ (champs lexico-sémantiques)..................................-- ៣១

៣.១- វិចារណកម្មទូទៅ ...........................................................................................-- ៣១

៣.២- សិក្សាលំអិតពីបរិវេណមួយប្រភេទៗ .................................................................-- ៣៣

៣.២.១- បរិវេណ.ស័ព្ទ-ន័យសាស្ត្ររូបនិយម
(champs sémasiologiques) ..............................................................-- ៣៣

៣.២.១.១- បរិវេណជាតិស័ព្ទ (champs étymologiques) ..........................................-- ៣៣

៣.២.១.២- បរិវេណពាក្យកម្លាយ (champs dérivationnels).......................................-- ៣៤

៣.២.១.៣- បរិវេណវចនស័ព្ទ (champs lexémiques)..................................................-- ៣៥

៣.២.២- បរិវេណ.ស័ព្ទ-ន័យសាស្ត្របញ្ញត្តិនិយម
(champs onomasiologiques) ...........................................................-- ៣៥

៣.២.២.១- បរិវេណអតិបូរណន័យតា (champs archi-séméniques)...........................-- ៣៥

៣.២.២.២- បរិវេណសមាគតភាព (champs associatifs) ...........................................-- ៣៥

៣.២.៣- បរិវេណល្បាយ (champs mixtes) .............................................................-- ៣៦

**គន្លងនិទ្ទេស** ..........................................................................................-- ៣៧

**បញ្ជីពាក្យបច្ចេកទេស ដែលមាន ក្នុងសិក្ខាកថានេះ** .............................................-- ៣៨

# ន័យកម្មវិទ្យា (sémiologie)

## សញ្ញាណទូទៅ :

## I- សញ្ញាណទូទៅលើបញ្ញត្តិមូលដ្ឋាន :

### ១ – សូរស័ព្ទភាសា ឬ សូរស័ព្ទ (signe linguistique).

ការសង្កេត : យើងអាចប្រែវិញ្ញត្តិ[១] បារាំង "signe linguistique" ថា "សញ្ញាភាសា" ប៉ុន្តែក្នុងភាសាខ្មែរ "សញ្ញា" ច្រើនសម្គាល់អ្វីដែលជាគំនូស (ផ្ទុយពីសូរ) រីឯ "signe linguistique" វិញ គឺជាសូរដែលផ្ទុយពីគំនូសនេះឯង ដូច្នេះហើយ គប្បីយើងប្រែថា "សូរស័ព្ទភាសា ឬ សូរស័ព្ទ" វិញ។

### ១.១ – អ្វីហៅថា "សូរស័ព្ទភាសា"?

មុនកំណើត linguistique[២] អ្វីដែលហៅថា "mot" ក្នុងភាសាបារាំង ("ពាក្យ" ក្នុងភាសាខ្មែរ) ជាផ្លាកសំរាប់សម្គាល់វត្ថុឬគំនិតផ្សេងៗ។ តាមភាសាវិទ្យា ការយល់បែបនេះជាការភាន់ច្រឡំទាំងស្រុង ដូច្នេះហើយ លោក សូស្សៀរ (Ferdinand de Saussure) ក៏បានឈប់ប្រើវចនស័ព្ទ "mot" នេះទៅ ហើយ បញ្ចូលវិញ្ញត្តិ "signe linguistique" (សូរស័ព្ទ ភាសា) មកជំនួសវិញ។ បើគាត់ទុកវចនស័ព្ទ "mot" គាត់មិនអាចកំចាត់ន័យថា "ផ្លាក" បានទេ ពីព្រោះ កាលណាគេឮ "mot" គេនឹកទៅ "ផ្លាក" ភ្លាម។ តាមការភាន់ច្រឡំនេះ ភាសានីមួយៗជាសារព័ន[៣] ផ្លាកមួយចំនួនធំដែលគេសម្រាប់បិទលើវត្ថុឬគំនិត ដែលមានក្នុងលោក ហើយ ភាសាពីរជាសារព័នផ្លាកពីរចំនួនដែលមានឈ្មោះប្លែកគ្នាសម្រាប់បិទលើវត្ថុឬគំនិតដូចគ្នាដែលមានក្នុងលោក។

ដើម្បីបង្ហាញអោយឃើញថា ការយល់បែបនេះជាការភាន់ច្រឡំទាំងស្រុង យើងអាចយកការបកប្រែមកពិនិត្យជាបឋម។ បើភាសាពីរជាសារព័នផ្លាកពីរចំនួនមែននោះ យើងត្រូវមានលទ្ធភាពសងផ្លាករបស់ភាសាមួយទៅផ្លាករបស់ភាសាមួយទៀត ដោយស្វ័យប្រវត្តិ។ ឧទាហរណ៍ : បារាំង "table" = ខ្មែរ

---

[១] ពាក្យ "វិញ្ញត្តិ" នេះមានក្នុងវចនានុក្រម បារាំង-ខ្មែរ របស់លោក តិបយក់ និង ថាវ គន្ធ គឺជាពាក្យសម្រាប់ប្រែពាក្យបារាំង "expression" ។

[២] ពាក្យ "linguistique" ត្រូវគេបង្កើតឡើង ដើម្បីសម្គាល់ការសិក្សាពីភាសាបែបថ្មី ដែលយករូបវិទ្យាជាគំរូផ្ទុយពីការសិក្សាពីភាសាដែលមានមកជាច្រើនសតវត្សរួចមកហើយ ដែលយកទស្សនវិទ្យាជាបង្អែក។ បើយើងប្រែ "linguistique" ថា "ភាសាវិទ្យា" គប្បីយើងគោរពន័យរបស់ពាក្យ "linguistique" គឺប្រើពាក្យ "ភាសាវិទ្យា" សម្រាប់តែការសិក្សាណាដែលយករូបវិទ្យាជាគំរូ ។

[៣] ក្នុងន័យកម្មវិទ្យានេះ ខ្ញុំប្រើពាក្យ "សារព័ន" ដើម្បីសងពាក្យបារាំងថា "un ensemble" ។

"តុ"; បារាំង "table des matières" = ខ្មែរ "* តុមុខវិជ្ជា"; បារាំង "table de multiplication" = ខ្មែរ "* តុលេខគុណ" - ល-។ តែផ្ទុយទៅវិញ យើង សង្កេតឃើញថា "* តុមុខវិជ្ជា" និង "* តុលេខគុណ" មិនអាចសម្គាល់អ្វីទេក្នុងភាសាខ្មែរ ÷ ការយកផ្លាក "តុ" ទៅសងផ្លាក "table" ជាទូទៅ/ជាស្វ័យប្រវត្ត បានចេញជាលទ្ធផលឥត ប្រើការបាន។

<u>កំណត់សម្គាល់</u> : - សញ្ញា " * " មានន័យថា កន្សោមពាក្យដែលនៅខាងស្តាំ
ជាកន្សោមពាក្យឥតត្រឹមត្រូវ ក្នុងភាសាខ្មែរ។

តាមពិត ជាតិនីមួយៗបានមើលឃើញវត្ថុដែលមានក្នុងលោក តាមរយៈសតិអារម្មណ៍ តាមរយៈអារ្យធម៌របស់គេ។ ភាសាបារាំងបានចែកផ្លូវទឹកជា "torrents, ruisseaux, rivières, fleuves" បានចែកពណ៌ជា១៣ពណ៌ មាន "blanc, noir, rouge, jaune, orange, bleu, vert, azur, marron, etc..." ដែលភាសាខ្មែរមិនអាចសងប៉ាច់ៗទៅវិញបានឡើយ។ ដូចគ្នានេះដែរ គំនិតដែលទាក់ទងនឹងឈើ/ព្រៃក៏ឥតមានការបែងចែកដូចគ្នាពីភាសាមួយទៅភាសាមួយដែរ ÷ ពាក្យខ្មែរ "ឈើ" ត្រូវនិងពាក្យ "arbre" ផង, និង ពាក្យ "bois"ផងក្នុងភាសាបារាំង។ រីឯ ពាក្យ "ព្រៃ" នៃភាសាខ្មែរវិញ វាត្រូវនឹងពាក្យ "forêt"ផង, ពាក្យ"bois"ផង, ពាក្យ"bosquell"ផង, ពាក្យ"clairière"ផង, ពាក្យ "jungle"ផង នៃភាសាបារាំង -ល-។ តារាងខាងក្រោមនេះ[៤] បង្ហាញអោយឃើញកាន់តែជាក់ស្តែងទៅទៀត នូវការបែងចែកធាតុធម្មជាតិប្លែកៗគ្នាទៅតាមជាតិសាសន៍ :

| Français | Anglais | Breton | Espagnol | |
|---|---|---|---|---|
| 1. bois | 1. wood | 1. Koad | 1. madera | (matière) |
| | | | 2. bosque | (forêt) |
| | | 2. Keuneud | 3. leña | (chauffage) |
| | 2. timber | 3. prenn | 1. madera | (charpente) |

<u>តារាង១</u>

ឧទាហរណ៍ទាំងប៉ុន្មានខាងលើបានបង្ហាញអោយឃើញថា ពាក្យមិនមែនជាផ្លាកទេ ហើយ មកពី "ពាក្យ" ធ្វើអោយនឹកដល់ផ្លាកភ្លាម សូសៀរក៏យកកន្សោម "សូរស័ព្ទភាសា" មកជំនួសវិញ ហើយ គាត់បានបញ្ជាក់ថា សូរស័ព្ទភាសាមិនមែនជាសហកម្ម (union) រវាងឈ្មោះមួយនិងវត្ថុមួយទេ ប៉ុន្តែ ជា

[៤] តារាងខ្ចីពីលោក Jean-Yves Urien សាស្ត្រាចារ្យនៅសាកលវិទ្យាល័យរ៉ែនទី២ (Rennes II) ប្រទេសបារាំង។

សហកម្មរវាងបញ្ញត្តិ (concept) និងទម្រសូរ (support acoustique) ឬ រវាងន័យករ (signifiant) និងន័យបញ្ញត្តិ (signifié) ។ គាត់តាងសូរស័ព្ទ ភាសា ដូចតទៅ ÷




រូបសញ្ញា ១

សញ្ញាព្រួញសម្គាល់ជំនាប់ឥតគម្លាតរវាងន័យករ និង ន័យបញ្ញត្តិ : បើគេចាប់អារម្មណ៍លើន័យករ គេមិនអាចទុកដោយឡែកនូវន័យបញ្ញត្តិបានឡើយ ហើយ បញ្ច្រាសទៅវិញក៏ដូចគ្នាដែរ : បើគេចាប់អារម្មណ៍លើន័យបញ្ញត្តិ គេក៏មិនអាចទុកដោយឡែកនូវន័យករបានដែរ ។

## ១.២ - លក្ខណៈនៃសូរស័ព្ទភាសា

លោក សូសៀរ បានផ្តល់លក្ខណៈជាច្រើនសម្រាប់សូរស័ព្ទភាសា ប៉ុន្តែ ខ្ញុំសុំបង្ហាញតែលក្ខណៈមួយបែបដែលជាលក្ខណៈសំខាន់ខ្លាំងក្នុងការសិក្សាអំពីភាសា ។

ចំពោះ លោក សូសៀរ ដែលបានប្រើជាឧទាហរណ៍នូវពាក្យទោល ដូចជា "arbor" (នៃភាសាឡាតាំង) និង "ox" (នៃភាសាអង់គ្លេស) នោះ សូរស័ព្ទភាសាមានលក្ខណៈអាជ្ញានិម្មិត (arbitraire) ក្នុងន័យថា "យកន័យករណាដាក់ជាមួយន័យបញ្ញត្តិណាក៏បាន" ស្រេចតែគេសន្មត ឬ ក្នុងន័យថា វាមានលក្ខណៈសេរី ឬ លក្ខណៈសិប្បនិម្មិត (artificiel) គឺគ្មានការបង្ខំពីធម្មជាតិទេ (សូម្បីតែតម្រាប់សូរ (onomatopée) ក៏មានលក្ខណៈសិប្បនិម្មិតដែរ ពីព្រោះ ភាសានីមួយៗត្រាប់សូរដោយសេរី (ឧ.ចំពោះសម្លេងមាន់រងាវភាសាបារាំងថា "cocorico" ភាសាអង់គ្លេសថា "cock-a-doodle-doo" ភាសាខ្មែរថា "កាកែកីកឺត" ទៅវិញ) ។

ដោយផ្អែកលើគំនិតរបស់ Emile Benveniste, វចនានុក្រមភាសាវិទ្យា[៥] បានសរសេរថា : "ការអះអាងបែបនេះ (ចំណងរវាងន័យករនិងន័យបញ្ញត្តិជាចំណងអាជ្ញានិម្មិត) បានផ្អែកលើវត្ថុដោយឥតបញ្ចេញឈ្មោះ(...) ។ អ្វីដែលមានលក្ខណៈអាជ្ញានិម្មិត គឺចំណងរវាងសូរស័ព្ទភាសា (...)និងវត្ថុនៃពិភពក្រៅភាសាវិញទេ" ។

[៥] Jean Dubois & alii, Dictionnaire de linguistique, Larousse 1980 .

OGDEN និង RICHARDS ក៏មានយោបល់ដូចខាងលើនេះដែរ គាត់បានបន្ថែម មុមទី៣ អោយសូរស័ព្ទភាសារបស់ លោក សូស្សេរ ។ នេះជាការគោងរបស់ក្រុមគាត់ :




រូបសញ្ញា ៣

គំនិតភាសាវិទូទាំងប៉ុន្មានខាងលើនឹងអាចត្រឹមត្រូវទៅបាន លុះណាសូរស័ព្ទភាសាមានន័យករ/សូរទម្រ ។ តែផ្ទុយទៅវិញ លោក សូស្សេរ បានបញ្ជាក់យ៉ាងច្បាស់ថា : "អ្វីដែលយើងហៅថា សូរស័ព្ទភាសា គឺឯកតាសរុបដែលមានន័យករផងនិងន័យបញ្ញត្តិផង[៦]" ។

ការយល់ពីលក្ខណៈសិប្បនិម្មិតនេះមានប្រយោជន៍ធំណាស់ក្នុងការឈ្វេងយល់ដល់ការវិវឌ្ឍរបស់ន័យនៃពាក្យ ។ បើយើងយល់លក្ខណៈនេះហើយ យើងមិនគប្បីខំទប់ទល់ចង់រក្សាទុកន័យដើមរបស់ពាក្យតាំងពីបុរាណកាលមកទេ ពីព្រោះយើងដឹងថា ន័យមិនមែនជាចំណងធម្មជាតិ ដែលគេចងជាប់នឹងវត្ថុនានានោះឡើយ ។ ដោយសារលក្ខណៈអាជ្ញានិម្មិតបែបនេះ បើយើងចង់ទប់វាក៏យើងមិនអាចទប់បានដែរ ។ ម្យ៉ាងទៀត យោងតាមលក្ខណៈដដែលនេះ យើងយល់ថា យើងអាចដោយសេរីប្រើពាក្យបច្ចេកទេស ដែលយើងត្រូវការ ហើយ យើងគ្រាន់តែកំណត់ន័យអោយពាក្យទាំងនោះទៅវាជាការស្រេច (ទោះពាក្យទាំងនោះត្រូវបានយើងខ្ចីពីភាសាបរទេស ឬ ត្រូវបានយើងបង្កើតថ្មីក៏ដោយ) ប៉ុន្តែ យើងគប្បីលៃយ៉ាងណាផងដែរ កុំឱ្យពាក្យទាំងនោះមានភាពរប៉ាត់រប៉ាយ ឥតចងជាចង្កោម ឥតរួមជាសន្តានជាមួយគ្នា ។ ពាក្យបច្ចេកទេសសម្គាល់អ្វីៗក្នុងវិទ្យាសាស្ត្រសឹងសុទ្ធតែជាពាក្យដែលចងជាចង្កោមក្នុងភាសាបារាំងឬអង់គ្លេស : បើយើងខ្ចីពាក្យពីគេផងនិងបង្កើតពាក្យថ្មីចេញពីភាសាខ្មែរ ឬ បាលិ-សំស្ក្រឹតផង យើងនឹងបង្កើតភាពរប៉ាត់រប៉ាយក្នុងភាសាខ្មែរមិនខាន ។

**១.៣ - ប្រភេទន័យរបស់សូរស័ព្ទភាសា :**

**១.៣.១ - ន័យកម្ម** (signification) :

[៦] Ferdinand de Saussure, Cours de linguistique générale, Payot 1959 , p.100 : "(…) nous entendons par signe le total résultant de l'association d'un signifiant à un signifié (…)".

ន័យកម្មជាន័យមូលដ្ឋាន ជាន័យទូទៅកើតឡើងពីសហកម្មរវាងន័យករនិងន័យបញ្ញត្តិ គឺជាន័យនៅក្នុងប្រព័ន្ធវេយ្យាករណ៍។ បើគេរកន័យកម្មនៃពាក្យ "table" ក្នុងភាសាបារាំង គេត្រូវលៃយ៉ាងណាកុំឱ្យពាក្យនេះសម្គាល់តែវត្ថុ១បែបដែលមានផ្ទៃរាបធ្វើពីឈើ/ថ្មទ្រដោយជើងបី/បួនសម្រាប់ដាក់ដៃសរសេរឬសម្រាប់ដាក់ម្ហូបអាហារ។ គេត្រូវរកន័យទូលាយឱ្យគ្របដណ្ដប់លើអ្វី១ទាំងប៉ុន្មានដែលមានពាក្យ "table" នេះជាបង្គោល ដូច table d'écolier, table de multiplication, table des matières, table d'écoute,... ។ *ន័យកម្ម* ជាផលវិភាគនៃភាសាវិទូតាមជាក់ស្ដែងមិនទាន់មានវចនានុក្រមណាបានស្វែងរក *ន័យកម្ម* បែបនេះជាទូទៅនៅឡើយទេ។

**១.៣.២ - <u>ន័យ (sens)</u> :**

ន័យរបស់ពាក្យណាមួយគឺអ្វី(បញ្ញត្តិ)ដែលពាក្យនោះសម្គាល់។ ន័យប្លែកពីន័យកម្មត្រង់ថា ន័យឥតមានអរូបិយភាពខ្លាំងដូចន័យកម្មទេ ពីព្រោះ ន័យឋិតនៅក្នុងប្រព័ន្ធទម្លាប់វាចាទម្លាប់នៃការប្រើប្រាស់ភាសា : ន័យមិនអាចមានវង្វង់ធំធេងដូចន័យកម្មទេ ពីព្រោះ វាលំឱនទៅតាមកាលៈទេសៈ ទៅតាមក្រុម/សហគមន៍ ទៅតាមបរិបទ។ តាមធម្មតា វចនានុក្រមឱ្យត្រឹមតែន័យស្នូលរបស់ពាក្យដែលគេហៅថា អត្ថានុរូប (sensproprе) រីឯន័យប្រយោលបន្ទាប់បន្សំ គេតែងបន្ថែមតាមលំហៅថា អត្ថបដិរូប (sens figuré)។ តាមភាសាវិទូមួយក្រុម[៧] ន័យជាវេវចនស័ព្ទជាមួយនិងន័យបញ្ញត្តិ (signifié)។

**១.៣.៣ - <u>យោង (ការយោង)</u> :**

ពាក្យ "យោង(ការយោង)" យោបោងជាចំណងរវាងសូរស័ព្ទភាសាណាមួយនិងអ្វីណាមួយនៃប្រភពខាងក្រៅ (ទោះអ្វីនោះជាវត្ថុ ឬ ជារូបារម្មណ៍ក៏ដោយ)។ តាម Roland Eluerd[៨] លោក Frège បានបង្ហាញអោយដឹងថា សូរស័ព្ទភាសាច្រើនម៉ាត់/ច្រើនកន្សោម ដែលមានន័យប្លែកគ្នាអាចមានការយោងទៅរកអ្វីតែមួយជាមួយគ្នា ឧទាហរណ៍ : "<u>Venus</u>, l'Etoile du Berger, l'Etoile du matin (...)". ។ <u>Venus</u> ជាឈ្មោះផ្កាយមួយបែប រីឯ l'Etoile du Berger ឬ l'Etoile du matin ដែលមានន័យផ្សេងគ្នាក៏សម្គាល់ផ្កាយដដែលនេះដែរ (យោងលើ/សម្គាល់វត្ថុតែមួយ)។

**១.៣.៤ - <u>ន័យវត្ថុនិមិត្ត (dénotation) & ន័យអត្ថនិមិត្ត (connotation)</u>.**

---

[៧]: J.L. CHISS, J. Filliolet & D. Maingueneau , Initiation à la problématique structurale, tome1, Hachette 1981.

[៨]: Cf. Roland Eluerd, La pragmatique linguistique, Nathan 1985, p.25 .

ន័យ.វត្ថុនិម្មិតមានសភាពផ្ទុយគ្នានឹងន័យអត្ថនិម្មិត ។ ន័យវត្ថុនិម្មិត/សត្យានុម័តជាន័យកម្មឋិតថេរ នៃសូរស័ព្ទភាសាណាមួយ ដែលគេចាប់យកក្រៅការប្រើប្រាស់បិរបទពិសេសណាមួយនៃសូរស័ព្ទភាសានោះ គឺជាន័យកម្មដែលមិនទាន់មានអញ្ញថាភាពមកឡុកឡំ ។

ន័យបុគ្គលនិម្មិតជាន័យពិសេសដែលមានជាប់ពាក់ព័ន្ធជាមួយជីវិត/កាលៈទេសៈរបស់បុគ្គលណាម្នាក់ ឬរបស់សហគមន៍នៅដំណាក់កាលណាមួយ : ឧទាហរណ៍ ពាក្យ "យប់" មានន័យ.វត្ថុនិម្មិតថា "ចន្លោះពេល នៅក្រោយថ្ងៃលិចនិងនៅមុនថ្ងៃរះ" ហើយ អាចមានន័យអត្ថនិម្មិត "ទុក្ខសោក/អវសានជីវិត" ក្នុងភាសា បារាំង ។ ក្នុងភាសាខ្មែរ "ជារនោជនៃជីវិត" ។

## ១.៤ – ព្រំដែន : តើសូរស័ព្ទភាសានៅត្រង់ណា ?

លោក សូរសៀរ បានបញ្ជាក់ស្ថានភាពនៃសូរស័ព្ទភាសាច្បាស់លាស់ល្អណាស់ ឆ្ពោះមុខទៅរក ធម្មជាតិ ឬ ទៅរកគំនិតនានា (គឺមិនមែនជាតំបាតនៃអ្វីៗទាំងនោះទេ) ប៉ុន្តែ ក្នុងខ្សែសម្តី គាត់ឥតបាន បញ្ជាក់ថា តើគេត្រូវធ្វើយ៉ាងណា ដើម្បីអោយដឹងថាសូរស័ព្ទភាសានីមួយៗចាប់ផ្តើមពីកន្លែងណា ហើយ ត្រូវចប់នៅកន្លែងណានោះទេ ។ "ox" (នៃភាសាអង់គ្លេស) និង "bœuf" (នៃភាសាបារាំង) ដែលគាត់ បានទាញជាឧទាហរណ៍ គឺជាសូរស័ព្ទភាសាមួយម៉ាត់ចុះ "au fur et à mesure" មានសូរស័ព្ទភាសា ប៉ុន្មានម៉ាត់ ? ចុះក្នុង "géographie" ? ក្នុង "contresens" ? ក្នុង "bon sens" ? មានសូរស័ព្ទ ភាសាប៉ុន្មានពាក្យទៅ? ។ ចំពោះ អង់ដ្រេ ម៉ារទីណេ (André Martinet) "gaîté" ឬ "donnait" ជា សូរស័ព្ទភាសា ហើយ នៅក្នុងនេះ ចំណែកតូចៗពីរ ដែលនៅមានន័យនៅឡើយ (បើគេយកចំណែកតូច ជាងនេះទៅទៀត ចំណែកតូចចុងក្រោយនេះឈប់មានន័យអ្វីទៀតហើយ) ក៏ជាសូរស័ព្ទភាសាដែរ គឺ "gai"/ "té" និង "donne"/ "ait" ។ ឆ្លៀតស្ថានភាពដែលគេមិនទាន់អាចកំណត់ព្រំដែនសូរស័ព្ទភាសាបានដោយ ប្រាកដប្រជា ហ្សង់ ឌុយប័រ (Jean Dubois) បានចាត់ទុកល្បះថា ជា "signe" មួយដែរ គឺជា "grand signe" (សូរស័ព្ទធំ) ។

តាម Claude Hagège[៥], Chomsky (ឆុមស្គី)ក៏បានទុកល្បះជាសូរស័ព្ទភាសាមួយបែបដែរ គឺសូរស័ព្ទធំ : "ឆុមស្គីបានចាត់ទុកថា ទ្រឹស្តីស្តីពីសូរស័ព្ទភាសាត្រូវបានគេបង្កើតមុន គាត់រួចហើយ ហើយគាត់ ត្រូវគិតពីល្បះវិញ ដែលជាសូរស័ព្ទភាសាផងដែរ ដែលគេមិនទាន់បានសិក្សាគ្រប់ជ្រុងជ្រោយ នៅឡើយ" ។

តាមរយៈឧទាហរណ៍ទាំងប៉ុន្មាននេះ យើងឃើញថា សូរស័ព្ទភាសាចោទបញ្ហាព្រំដែនដ៏លំបាក ។

---

[៥] Claude Hagège, La grammaire générative, réflexions critiques, PUF 1976, p. 218 .

**២ - ពាក្យ** (mot).

សព្វថ្ងៃនេះ វចនតា "mot"នៃភាសាបារាំង ដែលត្រូវនឹងវចនតា"ពាក្យ"[១០] ក្នុងភាសាខ្មែរឈប់មានន័យថាជាផ្លាកទៀតហើយ ក្នុងមជ្ឈដ្ឋានអ្នកចេះដឹង ដូច្នេះហើយ គេចូលចិត្តយក "mot" មកប្រើវិញ ពីព្រោះ វាមិនមែនជាកន្សោមពាក្យ ដូច "signe linguistique" ដែលជាខ្សែសម្តីវែងអន្លាយ ។ ប៉ុន្តែ គេមានបញ្ហាក្នុងការកំណត់ព្រំដែនពី "mot" ទៅ "mot " មួយក្នុងខ្សែសម្តី : គេមិនអាចដឹងដោយងាយក្នុងខ្សែសម្តីថា តើ"mot"ណាបានចាប់ផ្តើមពីត្រង់ណា ហើយ ត្រូវចប់នៅត្រង់ណាទេ។ វេយ្យាករណ៍និយាមបារាំងបានចែកពាក្យបារាំងជាប្រាំបួនប្រភេទ គឺ articles, noms, pronoms, adjectifs, verbes, adverbes, prépositions, conjonctions & interjections ។ គេថា "les" ជាពាក្យមួយម៉ាត់ គឺជា "article" តែ "les pommes de terre" ក៏ជាពាក្យមួយម៉ាត់ដែរ (ពាក្យសមាស) ដូច្នេះ ឃើញថា យើងពិបាកសម្គាល់ព្រំដែនពាក្យបារាំង[១១] ណាស់ ហើយ ម៉ារទីណេ ក៏បានបញ្ចូលបញ្ញត្តិ "monème" (មូលតា) ក្នុងការសិក្សាអំពីភាសាវិញម្តង ពីព្រោះគេអាចសម្គាល់ព្រំដែនរបស់ monème ដោយងាយ ។

**៣ - មូលតា** (monème) & **សទ្ទតា** (phonème) :

**៣.១ - មូលតា :**

ចំពោះ អង់ដ្រេ ម៉ារទីណេ (André Martinet) ភាសារបស់មនុស្សមានលក្ខណៈប្លែកខ្លាំងពីអ្វីៗដែលគេហៅថាភាសាផងដែរ ដោយរំលោភន័យថា ភាសាឃ្មុំ/ភាសាស្វា/ភាសា បក្សីបក្សា.... ។ លោក ម៉ារទីណេ បានបង្ហាញអោយឃើញថា ភាសាមនុស្សមានសន្និយោគពីរ ជាន់[១២] (double articu-lation) : ជាន់ទី១មានមូលតា ហើយ ជាន់ទី២មានសទ្ទតា។ មូលតាជាឯកតាអប្បបរមា ដែលមានន័យក្នុងភាសា ដូចពាក្យទោល (ពាក្យឫស) ÷ "voilà", "notre", "père" ឬដូច ÷ បុព្វបទ "em--", វិភត្តិ "--ons", ឫស "--barqu--" ដែលមានក្នុងពាក្យ "embarquons" ។ យើងអាចតាងគំនិតលោក ម៉ារទីណេ តាមរូបមន្ត ដូចខាងក្រោមនេះ ÷

---

[១០] ក្នុងស្មារតីខ្មែរភាគច្រើន វចនស័ព្ទ "ពាក្យ" នៃភាសាខ្មែរធ្វើអោយគេនឹកដល់ផ្លាកនៅឡើយ ហើយ ជាពិសេសនឹកដល់ពាក្យសរសេរ ដែលផ្ទុយពីសូរស័ព្ទភាសា ។

[១១] ក្នុងការសម្គាល់ព្រំដែន ពាក្យខ្មែរក៏មានបញ្ហាដែរ ហើយ មានតែលើសពីពាក្យបារាំងផងទៀត ។

[១២] ពាក្យ"សន្និយោគ"(articulation)ជាពាក្យខ្ចីពីវចនានុក្រមបារាំង-ខ្មែរ របស់លោក គិប យក់ និង ថាវ គន្ធ ។

| មូលតា = ឯកតាអប្បបរមាដែលមានន័យ |
| --- |

យោងតាមសទ្ទានុក្រមនៃភាសាវិទ្យា របស់លោក ហ្សង់ ឌុយប័រ (Jean Dubois) និង ក្រុមគាត់ (Editions Larousse) យើងអាចប្រើរូបមន្ត ដូចតទៅ :

Monèmes ( មូលតា) = lexèmes( វចនតា) ឬ morphèmes ( រូបតា)

ផ្ទុយពីសូរស័ព្ទភាសាដែលពិបាកសម្គាល់ព្រំដែនមូលតាអាចលេចចេញពីខ្សែសម្តីដោយងាយ កាលណាគេប្រើតំណូរវិធី (commutation) ដូចដែលលោក ហ្សក មូណាំង (Georges Mounin) បានប្រើ ដូចតទៅ ÷

ឧទាហរណ៍ ÷ [vwalanɔtrəpɛr] ។ ក្នុងឃ្លានេះ គេអាចធ្វើតំណូរវិធីដូចតទៅ :

[vwalanɔtrəpɛr]
[--------------mɛr]
[--------------sœr]

ពីព្រោះ គេអាចដូរ [pɛr] ជាមួយ [mɛr] ឬ [sœr] បាននោះ គេអាចសន្និដ្ឋានថា [pɛr] មិនមែនជាភាគដែលត្រូវជាប់ជាប្រក្រតីទៅនឹងភាគខាងដើម [vwalanɔtrə] នោះទេ ។ ក្រោយពីបានប្រើតំណូរវិធី (ឬវិធីជំនួស) នេះមក យើងបានកាត់តំណ [pɛr] ចេញពីខ្សែសម្តី [vwalanɔtrəpɛr] ហើយ យើងអាចសន្និដ្ឋានថា កំណាត់ [pɛr] មានន័យផងដែរ ពីព្រោះ គេអាចដូរវាជាមួយឯកតា [mɛr] & [sœr] ដែលមានន័យក្នុងភាសាបារាំង ។

បើគេប្រើវិធីដដែលនេះ ដើម្បីបំបែក [pɛr] អោយកាន់តែតូច ដូចតទៅ :

- [pɛr] ~ [pɛl] ---> [ r ]
- [pɛr] ~ [par] ---> [ ɛ ]
- [pɛr] ~ [mɛr] ---> [ p ]

គេបានកំណាត់តូចៗ [p] , [ɛ] & [r] ដែលឥតមានន័យទេ : ដូច្នេះហើយ កំណាត់ [pɛr] នេះជាឯកតាអប្បបរមា ( តូចបំផុត) ដែលមានន័យ ( បើចុះទៅក្រោមទៀត ន័យនឹង ត្រូវបាត់បង់) ។

គេអាចប្រើវិធីតំណូរបែបនេះ ដើម្បីកាត់ខ្សែសម្តីដែលនៅសល់ជាពីរកំណាត់ [vwala] និង [nɔtrə] ក្នុងខ្សែសម្តី [vwalanɔtrəpɛr] មានតំណបីកំណាត់គឺ [vwala], [nɔtrə] & [pɛr] ដែលសុទ្ធតែជាឯកតាអប្បបរមាដែលមានន័យ ហើយ ដែលជា monènes ( តាម និយមន័យរបស់ម៉ារទីណេ) ដែលគប្បីយើងប្រែថា "មូលតា" នេះឯង ។

យើងប្រើតំណូរវិធីដដែលដូចខាងលើ ដើម្បីរកចំនួនមូលស័ព្ទក្នុងខ្សែសម្ដី [ɑ̃barkɔ̃] ដូចតទៅ :

- [ɑ̃bark<u>ɔ̃</u>] ~ [ɑ̃bark<u>e</u>] ---> [-ɔ̃]
- [<u>ɑ̃</u>barkɔ̃] ~ [<u>de</u>barkɔ̃ ] ---> [ɑ̃-]
- [ɑ̃<u>bark</u>ɔ̃] ~ [ɑ̃<u>magasin</u>ɔ̃] ---> [-bark-]

តំណ [ɑ̃---] ដែលជាបុព្វបទ, តំណ [---bark---] ដែលជាឫស & តំណ [----ɔ̃] ដែលជាវិភត្តិក៏ជាមូលតាដែរ ។

**៣.២ - <u>សទ្ទតា</u> :**

ការបំបែកឯកតា [pɛr] អោយទៅជាឯកតាតូចៗរហូតដល់ [p], [ɛ] & [r] គឺជាការចូលដល់ជាន់ទី២ គឺជាន់សទ្ទតា ។ ឯកតា [p] , [ɛ] & [ r ] ជាស័ទ្ទតា ហើយ យើងបានឃើញអំបាញ់មិញថាឯកតា [p], [ɛ] & [r] នេះគ្មានន័យទេ ក្នុងភាសាបារាំង :

| សទ្ទតា = ឯកតាអប្បបរមា ឥតន័យ សម្រាប់ផ្គុំអោយទៅជាមូលស័ព្ទ |
|---|

ចំពោះ លោក ហ្សង់ ហ្គាញ៉េប៉ាំង (Jean Gagnepain) វិញ ភាសាឥតមានសន្ធិយោគពីរជាន់ទេ វាមានត្រឹមតែសន្ធិយោគប៉ុណ្ណេះ តែពីរជាន់ដែលវាមានគឺពីរជាន់ក្នុងទម្រង់ គឺទម្រង់នៃន័យករ និង ទម្រង់នៃន័យបញ្ញត្តិ ។ គាត់តាងទម្រង់ពីរជាន់ ដូចខាងក្រោមនេះ :




<u>រូបសញ្ញា ៤</u>

<u>ពន្យល់</u> : - សញ្ញាព្រួយមុខពីរក្នុងរូបសញ្ញាខាងលើនេះបង្ហាញអោយឃើញថា សូរស័ព្ទភាសានីមួយៗនឹងអាចមានន័យច្បាស់លាស់ លុះណាមានសូរស័ព្ទភាសាឯទៀតនៅជាមួយ ដើម្បីកំណត់ព្រំដែន ។

តាមទស្សនៈខាងលើនេះ ភាសាមិនអាចមានសន្ធិយោគពីរជាន់ទេ ពីព្រោះ លុះណាមានសូរស័ព្ទភាសា (លុះណាមានទម្រង់) ទើបមានភាសា ។ សទ្ទតា ឬ សារព័នសទ្ទតា (un ensemble de

phonèmes) មិនទាន់ទៅជាសូរស័ព្ទភាសាភ្លាមទេ វាគ្រាន់តែជាសន្ទស្សន៍[១៣] (indice) សិននៃនិមិត្តរូប (symbole)។ រវាងនិមិត្តរូបនិងសូរស័ព្ទភាសាឥតមាននិរន្តរភាពទេ វាដាច់ពីគ្នាដូចមានក្នុងរូបសញ្ញា ខាងក្រោមនេះ :




រូបសញ្ញា ៥

**៤ - វចនតា** (lexème).

វចនស័ព្ទអាចជាពាក្យឫស (ដែល ហ្សង់ ឌុយប័រ បានហៅថា "mot simple") ដូច "គោ/ ក្របី" ឬ ជាឫស ដូច "all--" ក្នុងកិរិយាស័ព្ទ "aller" ឬ "-form-" ក្នុងពាក្យ "in-form-ation" ជាដើម ក្នុងភាសាបារាំង។ វចនស័ព្ទជាបង្គោលក្នុងការបង្កើតពាក្យ (ឬក្នុងការ បំបែកពាក្យ)។

**៥ - រូបតា** (morphème) & **ភាឡូរូប** (allomorphes).

រូបស័ព្ទជាធាតុអម ប្រើជាមួយបូរណស័ព្ទឬជាមួយល្បះ ឬ ប្រើជាមួយវចនាតា : ផ្ទាក់ឈ្នាប់/ អញ្ញាសបទ[១៤], និងវិភត្តិជាដើម។ ក្នុងអញ្ញាសបទមាន បុព្វបទ អន្តេបទ និង បច្ច័មបទ។ ក្នុងវិភត្តិមាន វិភត្តិរបស់នាមស័ព្ទ និង វិភត្តិរបស់កិរិយាសព្ទ (ភាសាខ្មែរឥតមានវិភត្តិ ទេ)។

រូបតាខ្លះអាចចេញជារូបស្រដៀងៗគ្នាទៅតាមបរិបទ (environnement / contexte) ដូចបុព្វបទ នៃកិរិយាហេតុក្នុងភាសាខ្មែរជាដើម ដែលមានរូបស្រដៀងៗគ្នាមួយចំនួន ដូចខាងក្រោម :

- [ប៉-] : ប្ដឹង < ដឹង ;
- [ផ-] : ផ្ទឹម < ទឹម ;
- [បញ់-] : បញ្ចូល < ចូល ;
- [បន់-] : បន្សុី < សុី ;
- [បម់-] : បំបួស < បួស ;
- [បង់-] : បង្អួត < អួត -ល-។

[១៣]: ពាក្យ "សន្ទស្សន៍" (indice) ជាពាក្យខ្ចីពីវចនានុក្រមបារាំង-ខ្មែរ របស់លោក តិប យក់ និង ថាវ គន្ធ។

[១៤]: "អញ្ញាសបទ" ជាពាក្យខ្ចីពីមូលភាពនៃការបង្កើតពាក្យថ្មី របស់លោក កេង វ៉ាន់សាក់ រោងពុម្ពទេព ភ្នំពេញ ១៩៦៤។

បន្ទែកផ្សេងៗ ដូច [ប៉-], [ផ-], [បញ់-], [បន់-], [បម់-], [បង់-],... ជាបណ្ដស័ព្ទ (allomorphes) របស់រូបស័ព្ទ /ប៉-/ តែមួយ ( ការប្រើបន្ទាត់ទ្រេតពីរស្របគ្នា /,,,/ និង ឃ្នាប [...] ជាវិធីខ្ចីពីស័ទ្ទតាវិទ្យា និង សូរវិទ្យា ) ។

ការប្រែប្រួលបន្តិចបន្តួចនៃរូបស័ព្ទ /ប៉-/ ជាលទ្ធផលនៃសម្រូបសូរ ។ ដើម្បីយល់ពី សម្រូបសូរនេះ យើងត្រូវផ្អែកលើតារាងសូរនៃសូរវិទ្យា ដូចខាងក្រោមនេះ ÷

| ទីបន្លឺ / រង្វះខ្យល់ | បន្លឺបបូរមាត់ | | | | បន្លឺបបូរ មាត់&ធ្មេញ | | បន្លឺធ្មេញ | | | | បន្លឺក្រអូម | | | | បន្លឺរបាំងក្រអូម | | | | បន្លឺ កន្ទើត | | បន្លឺ ដើមក | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សិថិល | | ធនិត | | សិថិល | | សិថិល | | ធនិត | | សិថិល | | ធនិត | | សិថិល | | ធនិត | | សិថិល | | សិថិល | |
| | - | + | - | + | - | + | - | + | - | + | - | + | - | + | - | + | - | + | - | + | - | + |
| ខ.ឱស្ឋជៈ (ខ.បន្ទុះ) | p | b | ph | | | | t | d | th | | c | | ch | | k | | kh | | | | ʔ | |
| ខ.នាសិកជៈ (ខ.បន្ទុះ) | | m | | | | | | n | | | | ɲ | | | | ŋ | | | | | | |
| ខ.ត្រដុស | | | | | | | s | | | | | | | | | | | | h | | | |
| ខ.រលាស់ (ខ.លំហូរ) | | | | | | | | r | | | | | | | | | | | | | | |
| ខ.រលាត (ខ.លំហូរ) | | | | | | | | l | | | | | | | | | | | | | | |
| ព្យញ្ជនៈកន្លះ | | | | | | w | | | | | | j | | | | | | | | | | |

តារាង ២

អក្សរកាត់ : ខ = ខ្យល់

ការពិនិត្យតារាងខាងលើបានបង្ហាញអោយឃើញថា ការសម្រូបសូរបានកើតឡើងក្រោមឥទ្ធិពលនៃទីបន្លឺនៃសូររបស់ពាក្យដើម ( ពាក្យដែលអោយកំណើតដល់ពាក្យកម្លាយ ) ÷

- បើពាក្យដើមមានសូរ [c] ( ច ) ដូចពាក្យ [co:l] ( ចូល ) រូបស័ព្ទ /p-/ ( /ប៉-/ ) ក្លាយទៅជា [baɲ-] ពីព្រោះ ទីបន្លឺរបស់សូរ [c] ទាញរូបស័ព្ទ /p-/ អោយមកជិតទីបន្លឺរបស់ខ្លួន ហើយ វាចេញជា [baɲ]ដែលមាន [ɲ-] នៅក្នុងនោះ គឺ [baɲco:l] ( បញ្ចូល ) ។
- បើពាក្យដើមមានសូរ [s] ( ស ) ដូចពាក្យ [si] ( ស៊ី ) រូបស័ព្ទ /p-/ ( /ប៉-/ ) ក្លាយទៅជា [ban-] ពីព្រោះ ទីបន្លឺរបស់សូរ [s] ទាញរូបស័ព្ទ /p-/ អោយមកជិតទីបន្លឺរបស់ខ្លួន ហើយ វាចេញជា [ban-]ដែលមាន [n-] នៅក្នុងនោះ គឺ [bansi] ( បន្ស៊ី ) - ៧ - ។

<u>សេចក្ដីបញ្ជាក់</u> : វិចនស័ព្ទក៏ជាមូលស័ព្ទ រូបស័ព្ទក៏ជាមូលស័ព្ទ ហើយ ស័ព្ទទាំងនេះសុទ្ធតែស័ព្ទតូចបំផុតដែលនៅមានន័យ ( បើគេធ្វើការបំបែកតទៅទៀត ន័យត្រូវបាត់-បង់ ហើយ គេនឹងធ្លាក់ចុះដល់ថ្នាក់ស័ទ្ទតា) ។ រូបសញ្ញាខាងក្រោមនេះអាចផ្ដល់រូបិយភាពអោយសេចក្ដីបញ្ជាក់ ដើម្បីអោយងាយយល់ :

Monèmes[១៥] ( មូលតា) ─┬─ lexèmes ( វិចនតា)
                       └─ morphèmes ( រូបតា)

**៦ - <u>បូរណាស័ព្ទ</u>** (lexie).

មូលស័ព្ទ ( វិចនស័ព្ទ និង រូបស័ព្ទ) ជាកំណាត់ក្នុងខ្សែសម្ដីដែលងាយសម្គាល់ ប៉ុន្តែ អ្នកប្រើប្រាស់ភាសាឥតមានលទ្ធភាពផ្គុំមូលស័ព្ទជាទូទៅដោយសេរីទេ ។ តំណរវាងមូលស័ព្ទខ្លះត្រូវភាសាបង្ខំឱ្យអ្នកប្រើប្រាស់ទទួលយកតែម្ដង ហើយ ចេញជាបូរណស័ព្ទ ដូច "cheval", "cheval- vapeur", "cheval marin" ជាដើម ក្នុងភាសាបារាំង ឬ ដូច "រដ្ឋធម្មនុញ្ញ", "រដ្ឋសភា", "ស្បែកជើង" - ល - ក្នុងភាសាខ្មែរ ។

តាម បែរណា ប៉ូជេ (Bernard Pottier) បូរណស័ព្ទជាកំណាត់ទោល (cheval) ឬ ជាកំណាត់ល្បាយ (cheval-vapeur/cheval marin) ដែលមានឯកភាព ដែលយើងមិនអាចកាត់តបែបណាទៀតបាន ហើយ ដែលយើងត្រូវប្រើទាំងមូល ។ បូរណស័ព្ទមាន ពាក្យឫស (mots-racines) ពាក្យកម្លាយ (mots dérivés) ពាក្យសមាស (mots composés) ពាក្យវាចាវិលាស[១៦] (locutions) កន្សោមពាក្យកាត់ (sigle) - ល - ដោយ "មូលស័ព្ទ" និង "បូរណស័ព្ទ" ជាបញ្ញត្តិថ្មី ខ្ញុំសុំប្រើរូបសញ្ញាខាងក្រោមនេះ ដើម្បីធ្វើអោយបញ្ញត្តិទាំងពីរមានលក្ខណៈរូបិយងាយយល់ :

---

១៥ : ភាសាវិទូអាមេរិកាំងនិងបារាំងអាមេរិកាំងនិយមប្រើពាក្យ morphème ជំនួសពាក្យ monème ។ ចំពោះពាក្យ lexème និង morphème ប្រើដោយភាសាវិទូបារាំង ភាសាវិទូអាមេរិកាំង និង អ្នកអាមេរិកាំងនិយមប្រើជាលំដាប់នូវពាក្យ morphème lexical និង morphème grammatical ទៅវិញ ។

១៦ : វាក្យសព្ទខ្មីពីវចនានុក្រមបារាំង-ខ្មែររបស់លោក តិប យក់ & ថាវ គន្ធ , បណ្ណាគារប៊ុតនាង ភ្នំពេញ ឆ្នាំ១៩៦២ ។




<u>រូបសញ្ញា ៦</u>

ដូចសូរស័ព្ទភាសានិងដូចពាក្យ ដូច្នោះដែរ បូរណស័ព្ទតែងចោទបញ្ហាដល់យើងចំពោះ ការកំណត់ព្រំដែនក្នុងខ្សែសម្តី ជាពិសេសចំពោះបន្លែករវាងបូរណស័ព្ទនិងកន្សោមសេរីកើតពីការផ្គុំពាក្យ ដើម្បីបញ្ចេញមតិ។ ដើម្បីដោះស្រាយបញ្ហានេះ ភាសាវិទូមួយក្រុម[១៧] បានបង្កើតតេស្ត (test) បួនបែប ដើម្បីជាបង្អែកសម្រាប់សម្គាល់បូរណស័ព្ទ សម្រាប់រកបន្លែករវាងបូរណស័ព្ទល្បាយ(ពាក្យសមាស) និង កន្សោមសេរីដែលគេផ្គុំដោយសេរី ដើម្បីបញ្ចេញគំនិតក្នុងការនិយាយស្តី។ ចំពោះពាក្យសមាសបារាំង តេស្តផ្អែកលើលក្ខណៈវិនិច្ឆ័យរូបនិយមបានផ្តល់លទ្ធផលគួរអោយពេញចិត្ត។ ចំពោះពាក្យសមាសខ្មែរវិញ ការអនុវត្តមិនទាន់ផ្តល់លទ្ធផលល្អគ្រប់លក្ខណៈនៅឡើយទេ : យើងត្រូវខំស្វះស្វែងត្រូវប្រឹងប្រែងខំរកតេស្តថ្មី ឬ វិធីថ្មីក្នុងការប្រើតេស្តដែលមានមកស្រាប់។

**៧ - <u>ការអនុវត្តតេស្តរកពាក្យសមាសបារាំង និង ការអនុវត្តបណ្តោះអាសន្នរកពាក្យសមាសខ្មែរ</u> :**

**៧.១ - <u>ការអនុវត្ត លើ កន្សោមពាក្យបារាំង</u>** ឧ. "pomme de terre" **:**

**៧.១.១** - <u>**តេស្តដែក** (test d'insertion)</u>:

---

[១៧] : សូមអាន Jean-louis CHISS et alii, Initiation à la linguistique structurale, tome 1, p.154, Hachette 1981.

ពាក្យសមាស ដែលកើតពីការផ្សំពាក្យច្រើន (ពីរ ឬ លើសពីពីរ) ត្រូវមានលក្ខណៈដូចពាក្យទោលដែរ គឺមិនអាចទទួលអង្គធាតុពីក្រៅណាមួយអោយដែកបំបែករូបសាស្ត្រខ្លួនជាពីរ/បីចំណែកឡើយ។ គេមិនអាចដាក់ពាក្យណាមួយក្នុងពាក្យពហុព្យាង្គដូចពាក្យ "ជំនួញ" ជាដើម។ គេមិនអាចថា "* ជំនេះនួញ" ក្នុងន័យថា "ជំនួញនេះ"ទេ ឬ ក៏គេមិនអាចថា "* ក្រចាស់បី" ក្នុងន័យថា "ក្របីចាស់" ដូច្នេះដែរ។ ចំពោះពាក្យសមាសក៏ដូចគ្នានេះដែរ ពីព្រោះ ក្នុងពាក្យសមាស សមាសភាពនីមួយៗបានរលាយចូលគ្នាទៅហើយ បើពុំនោះសោត កន្សោមពាក្យមិនមែនជាពាក្យសមាសទេ គឺជាកន្សោមសេរី។ ក្រោយពីបានរៀបរាប់ពីអត្ថន័យរបស់តេស្តដែក គប្បីយើងពិនិត្យមើលការអនុវត្តរបស់វា ដូចតទៅ :

- គេមិនអាចថា "* pomme nouvelle de terre"ទេ គេត្រូវថា "pomme de terre nouvelle";
- ប៉ុន្តែ ក្នុងកន្សោមសេរីដូចកន្សោម "permis d'exploitation" ជាដើម គេអាចដាក់គុណនាមនៅខាងក្នុង : "permis français d'exploitation"

<u>សេចក្តីសន្និដ្ឋាន</u> : តាមរយៈតេស្តដែក កន្សោម "pomme de terre" ជាពាក្យសមាស។

**៧.១.២ - <u>តេស្តកំណាត់</u>** <u>(test de répétition partielle)</u>:

ក្នុងតេស្តកំណាត់ គេកាត់កន្សោមពាក្យចោលមួយភាគ ក្រោយពីបានប្រើកន្សោមនោះទាំងមូលម្តងមកហើយ។ បើគេកាត់មិនបានទេ (ពីព្រោះ បើគេកាត់គេបានន័យផ្សេងទៅវិញ) កន្សោមនោះជាពាក្យសមាស :

- Ma mère a acheté 5 kg de <u>pommes de terre</u>; ces <u>pommes</u> sont très bonnes : កន្សោម "ces pommes" កាត់ចេញពី "de terre" មិនមែន "pommes de terre" ទេ ;
- ផ្ទុយទៅវិញ គេអាចថា "La France a envoyé beaucoup de <u>soldats de</u> <u>métier</u> au Tchad; ces <u>soldats</u> sont très combattifs : កន្សោម "ces soldats" ពិតមែនតែគ្មាន "de métier" នៅជាមួយ សម្គាល់ "soldats de métier" ដដែល។

<u>សេចក្តីសន្និដ្ឋាន</u> : តាមរយៈតេស្តកំណាត់ កន្សោមពាក្យ "pomme de terre" ជាពាក្យសមាស។

**៧.១.៣ - <u>តេស្ត (តំណាក់) កត្តារួម</u>** <u>(test de mise en facteur commun)</u> :

តេស្តទាំងអស់មានអត្ថន័យដូចគ្នា : បើតេស្តមិនអាចបំបែកបំបាក់សមាជិកក្នុងគ្រួសារ កន្សោមពាក្យណាមួយទេ កន្សោមពាក្យនោះមិនមែនជាកន្សោមសេរីទេ គឺជាកន្សោមផ្សារភ្ជាប់/កន្សោមល្អិត គឺជាពាក្យសមាស :

- គេត្រូវរកពីរ/បីកន្សោម ដែលមានទម្រង់សមាសភាពមួយដូចគ្នា ដូចជា "pomme de terre; "pomme d'Adam" & "pomme de pin" : គេមិនអាចថា "*pomme de pin, de terre et d'Adam" ទេ (ភាសាបារាំងមិនអនុញ្ញាត ការប្រើប្រាស់បែបនេះ)
- តែ គេអាចថា "chefs d'Etat et de gouvernement"

<u>សេចក្តីសន្និដ្ឋាន</u> : តាមរយៈតេស្តកត្តារួម កន្សោម "pomme de terre" ជាពាក្យសមាស ។

**៧.១.៤- <u>តេស្តតំណួរ</u>** <u>(test de commutation)</u> :

តេស្តតំណួរជាវិធីប្តូរចំណែក/សមាសភាពណាមួយនៃកន្សោមដែលយើងចង់ស្ទង់ជាមួយពាក្យណាមួយយកពីក្រៅរើសអោយសមស្របតាមស្ថានភាព : ចំពោះ "pomme de terre" យើងអាចប្តូរ "de terre" ជាមួយ "d'inter-saison" :

- បើគេប្តូរ "pomme de terre" ទៅជា "pomme d'inter-saison" បញ្ញត្តិ សម្គាល់ "pomme de terre" ត្រូវរលាយ ពីព្រោះពាក្យ "pomme" ក្នុង "pomme d'intersai-son" និង ក្នុង "pomme de terre" ឥតមានន័យ ដូចគ្នាទេ ;
- ផ្ទុយទៅវិញ បើគេប្តូរ "fauteuil à roulettes" ទៅជា "fauteuil à pédale" បញ្ញត្តិសម្គាល់ "fauteuil" នៅដដែល ។

<u>សេចក្តីសន្និដ្ឋាន</u> : តាមរយៈតេស្តតំណួរ កន្សោម "pomme de terre" ជាពាក្យសមាស ។

<u>កំណត់សម្គាល់</u> : តេស្តតំណួរជាតេស្តពិបាកប្រើ : តែ ដើម្បីអោយដឹងថាកន្សោម ដែលយើងស្ទង់ ជាពាក្យសមាសឬជាកន្សោមសេរី យើងអាចប្រើតេស្តតែបីក៏ជាការគ្រប់គ្រាន់ណាស់ទៅហើយ : យើងអាចសន្និដ្ឋានថា កន្សោមដែលយើងស្ទង់ ជាពាក្យសមាស១០០% ឬ ជាពាក្យសមាស តែត្រឹមកម្រិតណាមួយទៅតាមលទ្ធផលនៃតេស្តទាំងប៉ុន្មាននោះ ។

**៧.២ – <u>ការអនុវត្ត លើ កន្សោមពាក្យខ្មែរ</u>** "ស្បែកជើង" :

**៧.២.១ – <u>តេស្តថែក</u> :**

- គេមិនអាចថា "* ស្បែកថ្មីជើង * ស្បែកថ្មីរបស់ជើង" (ឬ * ស្បែកនៃជើង/

∗ ស្បែករបស់ជើង" ទេ គេត្រូវថា "ស្បែកជើងថ្មី";

- ផ្ទុយពីកន្សោមសេរី "ស្បែកគោ/ស្បែកស្គរ" ជាដើម ដែលអាចទទួលពាក្យរណប (complétif) ឬ ពាក្យឈ្នាប់ណាមួយ ដូចជា "ស្បែករបស់គោ" ឬ "ស្បែកសម្រាប់ដាសស្គរ" ។

<u>សេចក្ដីសង្កេត និង សេចក្ដីសន្និដ្ឋាន</u> :

(១) - បើគេថា "ស្បែកចាស់ស្គរ" លទ្ធផល ដែលបានមកជាកន្សោមមិនសមស្របតាមទម្លាប់នៃការនិយាយស្ដីរបស់ខ្មែរទេ ប៉ុន្តែ បើគេថា "ស្បែកស្គរចាស់" គេច្រើនយល់ថា អ្វីដែលចាស់នោះ គឺស្គរ : ដូច្នេះ ដើម្បីចៀសន័យពាំត្រណោត គេត្រូវថា "ស្បែកចាស់របស់ស្គរ" ទោះកន្សោមបែបនេះមិនសូវស្រួលស្ដាប់ក៏ដោយ ។ ការប្រើពាក្យ "នៃ"សម្រាប់ភ្ជាប់ពាក្យរណប (complétif) ទៅពាក្យបង្គោល (complété) ជាទម្លាប់ថ្មីក្នុងភាសាខ្មែរ ដែលជាហេតុនាំអោយទ្រគោះត្រចៀកក្នុងករណីខ្លះ ។ ប៉ុន្តែ ភាសានេះកំពុងស្វែងរកតម្លា : យើងមិនអាចទុកកន្សោមណាដែលមានន័យពាំត្រណោតអោយនៅដដែលតទៅទៀតទេ ។

(២) - ទោះបីការប្រើតេស្តមិនបានផ្ដល់លទ្ធផលល្អប្រពៃ ដូចការប្រើជាមួយកន្សោមបារាំង "pomme de terre" ក៏ដោយ យើងក៏អាចធ្វើសន្និដ្ឋានល្មមយកការបានជាបណ្ដោះអាសន្នថា : តាមរយៈតេស្តដែកនេះ កន្សោម "ស្បែកជើង" ជាពាក្យសមាស ។

### ៧.២.២- <u>តេស្ត(តំណាក់)កត្តារួម</u> :

ក្នុងភាសាខ្មែរ ការដាក់កត្តារួមមិនមែនឥតមានទេ ឧ. "<u>ការទូទាត់បំណុល</u>ថ្លៃទិញ ឬ ថ្លៃឈ្នួល"[១៨] ដែលនៅក្នុងនោះ កន្សោម "ការទូទាត់បំណុល"ត្រូវភ្ជាប់ទៅ "ថ្លៃទិញ" ផងនិង ទៅ "ថ្លៃឈ្នួល"ផង ឬ "លោក/អ្នកគ្រូ"/ "សេចក្ដីស្នេហា និង មោទនភាព<u>ជាតិ</u>"[១៩] ដែលនៅក្នុងនោះពាក្យ "គ្រូ"ជាកត្តារួមរបស់ "លោក" និងរបស់ "អ្នក" ហើយ ពាក្យ "ជាតិ" ជាកត្តារួម របស់ "សេចក្ដីស្នេហា"និងរបស់ "មោទនភាព" ។ ប៉ុន្តែ ក្នុងការភ្ជាប់ពាក្យបង្គោល (complété) ជាមួយពាក្យរណប (complétif) គេមិនសូវប្រើ "នៃ"ទេ ឧ. "ប្រមុខរដ្ឋ" / "ប្រមុខរដ្ឋាភិបាល" : ដូច្នេះហើយ យើងពិបាកប្រើតេស្តកត្តារួមជាទូទៅ ដើម្បីរកបន្ថែករវាងកន្សោមសេរីនិងកន្សោមល្អិតដែលជាពាក្យសមាសណាស់ ។ បើយើងដាក់កត្តារួម [ប្រមុខ (រដ្ឋ និង រដ្ឋាភិបាល)] យើងត្រូវបានកន្សោម "ប្រមុខរដ្ឋនិងរដ្ឋាភិបាល" ដែលមានន័យថា "ប្រមុខរដ្ឋ" និង "រដ្ឋាភិបាល" ។

---

[១៨] យោង : "សេចក្ដីជូនដំណឹង ស្ដីពីការទូទាត់...", <u>រស្មីកម្ពុជា</u> ថ្ងៃពុធ ០៦ - ០២ - ០២ , ទំព័រក១ ។

[១៩] យោង : *ភាសាខ្មែរ* ថ្នាក់ទី៧ ក្រសួងអប់រំ ក្នុងអារម្ភកថា និង នៅទំព័រ២ ឆ្នាំ ២០០១ ។ ការប្រើកត្តារួមថា "លោក/អ្នកគ្រូ"ជាការរំលោភលើទម្លាប់ដែលខ្មែរតែងតែថា "លោកគ្រូ អ្នកគ្រូ" ។

លុះណា យើងប្រើ "នៃ"ទើបយើងអាចភ្ជាប់ "ប្រមុខ" ទៅ "រដ្ឋ"ផង និង ទៅ "រដ្ឋាភិបាល" ផង : "ប្រមុខនៃរដ្ឋ និង នៃរដ្ឋាភិបាល" ( ការនិយាយបែបនេះមិនស្របតាមទម្លាប់ខ្មែរទេនៅបច្ចុប្បន្នកាលនេះ) ។

ចំពោះកន្សោម "ស្បែកជើង"វិញ បើយើងប្រើតេស្តកត្តារួម យើងបាន [ស្បែកគោ និង ជើង] = "ស្បែកគោនិងជើង" គឺ "ស្បែកគោ" និង "ជើង" : "ស្បែកជើង" ឥតមានអត្ថិភាព នៅទីនេះទេ ។

សេចក្តីសន្និដ្ឋាន : តេស្តកត្តារួមមិនអាចប្រើបានទេ ។

**៧.២.៣- តេស្តកំណាត់ :**

- យើងមិនអាចថា : "ម្តាយខ្ញុំបានទិញស្បែកជើងពីរគូ ស្បែកនោះល្អណាស់" ពីព្រោះ ស្បែកមិនមែនជាស្បែកជើងទេ ;
- ផ្ទុយពីនេះ គេអាចថា "ខ្ញុំបានទិញតុបាយពីរ កាលពីម្សិលមិញ ។ តុនោះល្អណាស់" : "តុនោះ" គឺជា "តុបាយ"ទាំងពីរនោះឯង ។

សេចក្តីសន្និដ្ឋាន : តាមរយៈតេស្តកំណាត់កន្សោម "ស្បែកជើង"ជាពាក្យសមាស ។

**៧.២.៤- តេស្តតំណូរ :**

យើងអាចដូរចំណែកណាមួយនៃកន្សោម "ស្បែកជើង" ជាមួយចំណែកនៃកន្សោមណា មួយ (ចំណែកមុខ ឬ ចំណែកក្រោយ) ដែលជាពាក្យដូចគ្នានឹងពាក្យដែលមានក្នុងកន្សោម "ស្បែកជើង" នេះ :

- យើងអាចដូរ"ស្បែកជើង"ទៅជា"ស្បែកគោ" ហើយ តាមរយៈវិធីនេះ យើងបានបំបែកចេញពីកន្សោម"ស្បែកជើង"នូវពាក្យ "ស្បែក" និងពាក្យ "ជើង" : ពាក្យ "ស្បែក" រក្សាន័យដើមជា "ស្បែក" ដដែល ។ ការបំបែកកន្សោម "ស្បែកជើង" ជាចំណែកមិនបានបំផ្លាញន័យរបស់ពាក្យ "ស្បែក" នៃកន្សោម "ស្បែកជើង"ទេ ។

សេចក្តីសន្និដ្ឋាន : ដូចយើងបានដឹងមករួចមកហើយ តេស្តតំណូរជាតេស្តពិបាកប្រើណាស់ : គេមិនអាចប្រើតេស្តនេះដើម្បីអោយដឹងថា "ស្បែកជើងជាពាក្យសមាសឬជាកន្សោមសេរីឡើយ ។

កំណត់សម្គាល់ : ដូចគ្នានឹងករណីពាក្យសមាសបារាំងដែរ គេអាចសន្និដ្ឋានថា កន្សោមដែលគេស្ទង់ជាពាក្យសមាស ១០០% ឬ ជាពាក្យសមាសតែត្រឹមកម្រិតណាមួយនោះ គឺអាស្រ័យទៅតាមលទ្ធផលនៃតេស្តទាំងប៉ុន្មាន ដែលគេបានប្រើ ។ ប៉ុន្តែ គេអាចប្រើតែតេស្តដែក និងតេស្តកំណាត់ ដើម្បីអោយដឹងថា កន្សោមពាក្យខ្មែរណាមួយជាកន្សោមសេរីឬជាពាក្យ-

សមាស ហើយ ភាគរយនៃកម្រិតល្អតក៏ត្រូវផ្អែកតែលើលទ្ធផលនៃតេស្តទាំងពីរនេះដែរ (0% , ៥0% , ១00%) ។

## II- សញ្ញាណទូទៅលើវិជ្ជាសន្ទាន/វិជ្ជាចិតខាងក្នា :

### ១ – ប្រវត្តិ នៃ បញ្ញត្តិមួយចំនួន និង វិជ្ជាពាក់ព័ន្ធ : ន័យកម្មវិទ្យា (sémiologie), សញ្ញាវិទ្យា (sémiotique) និង ន័យវិទ្យា (sémantique) :

កាលពីមុន ភាសាវិទូបារាំង (ដូចភាសាវិទូជាតិសាសន៏ឯទៀតដែរ) ស្គាល់តែវិជ្ជា "sémantique" មួយទេ។ ប៉ុន្តែ ប្រហែល៣0-៤0ឆ្នាំដែលកន្លងទៅប៉ុណ្ណេះ ទើបភាសាវិទូ បារាំងខ្លះ (មាន Jean Gagnepain ជាបឋម) បានចាប់ចែកមុខវិជ្ជា ដែលទាក់ទងនឹងន័យជាពីរមុខគឺ "sémiologie" (ន័យកម្មវិទ្យា) និង "sémantique" (ន័យវិទ្យា)[២0] ។

សូសៀរបានស្នើអោយបង្កើតវិជ្ជាថ្មីមួយសំរាប់សិក្សាពី "signes" ទូទៅ ហួសពី "signes linguistiques" ទៅទៀត (ដូច កាកបាទដែលសម្គាល់មន្ទីរពេទ្យ ភ្លើងបៃតង ដែលមានន័យថា "យើងអាចឆ្លងផ្លូវខ្វែង" ភ្លើងក្រហមដែលមានន័យថា "យើងត្រូវឈប់សិន ",...) គាត់បានសុំអោយគេហៅវិជ្ជានោះថា "sémiologie" ។

ក្រោយមក វិជ្ជាដែលសិក្សាពី "signes" គ្រប់បែបយ៉ាងក៏បានកើតឡើងមែន។ អ្នកបង្កើតខ្លះបានហៅថា "sémiologie" ដូចសម្នើរបស់សូសៀរ តែអ្នកខ្លះទៀតបានហៅថា "sémiotique" ទៅវិញ ហើយដល់ទីបញ្ចប់ ពាក្យ "sémiotique" (ដែលយើងអាចប្រែថា "សញ្ញាវិទ្យា") ក៏ត្រូវបានគេទទួលយកជាទូទៅ។ ពាក្យ "sémiologie" ក៏ត្រូវនៅទំនេរ ហើយ ហ្សង់ ហ្គាញើប៉ាំង (Jean Gagnepain) ក៏យកវាទៅប្រើសម្គាល់វិជ្ជា ដែលសិក្សាពីន័យក្នុងពិភពវេយ្យាករណ៍ ដែលគប្បីយើងប្រែថា "ន័យកម្មវិទ្យា" ដូចមានខាងលើនេះឯង (ន័យកម្មវិទ្យាប្លែកពីន័យវិទ្យាដែលជាវិជ្ជាសិក្សាពីន័យក្នុងពិភពទម្លាប់នៃការប្រើប្រាស់ភាសា/ពិភពទម្លាប់វាចា ដូចមានចែងក្នុងសង្គមភាសាវិទ្យារបស់ខ្ញុំស្រាប់) ។

---

[២0] : ការបែងចែកជា "sémiologie" និងជា "sémantique" ជាលទ្ធផលនៃការបែងចែកការសិក្សាពីភាសាជាពីរប្រព័ន្ធ គឺប្រព័ន្ធវេយ្យាករណ៍និងប្រព័ន្ធទម្លាប់ប្រើប្រាស់ភាសា/ប្រព័ន្ធទម្លាប់វាចា។ មុនមានការបែងចែកជាពីរមុខវិជ្ជានេះ គេប្រើពាក្យ "sémantique" ជាទូទៅ ប៉ុន្តែ គេប្រើពាក្យនេះសឹងសុទ្ធតែក្នុងន័យថា "sémiologie" ។

តាមរយៈប្រវត្តិខាងលើនេះ យើងបានស្គាល់ន័យ របស់ពាក្យ "sémiologie" របស់ "sémiotique" និង របស់ "sémantique" ហើយ។ តទៅនេះ ខ្ញុំនឹងលើកមកបង្ហាញនូវវិជ្ជាសន្តានឬវិជ្ជាជិតខាងគ្នា ដែលទាក់ទងនឹងន័យ & ន័យកម្ម។

**២ – រូបស័ព្ទវិទ្យា** (morphologie).

រូបស័ព្ទវិទ្យាជាវិជ្ជាដែលសិក្សាពីការផ្គុំរូបស័ព្ទ (morphèmes) ជាមួយឫស/ពាក្យឫស ដើម្បីបង្កើតពាក្យ។ ពាក្យដែលកើតដោយវិធីនេះ គឺជាពាក្យកម្លាយ ប៉ុន្តែ ការបង្កើតពាក្យមានវង្វង់ធំធេងជាងនេះឆ្ងាយទៅទៀត គឺមានការបង្កើត ពាក្យសមាស ពាក្យរណ្ដំ ពាក្យកាត់ ពាក្យកន្សោមកាត់ ដែលស្ថិតនៅក្នុងវិធីមួយដ៏ធំទូលាយតទៅទៀត ហៅថា "វិធីរូប ស័ទ្ទតានិយម" (procédés morphophonologiques) : ដូច្នេះហើយ រូបស័ព្ទវិទ្យាត្រូវនៅក្រោមវិជ្ជាដែលសិក្សាពីការបង្កើតពាក្យយ៉ាងទូលំទូលាយ ដូចយើងទើបបានរៀបរាប់រួចមក គឺវចនវិទ្យា (lexicologie) ។

**៣ – វចនវិទ្យា/ស័ព្ទវិទ្យា** (lexicologie).

ភាសាវិទ្យាជាវិជ្ជាដែលយើងចម្លងតាមប្រទេសជឿនលឿន ហើយ ស្ថានភាពច្បាស់លាស់ ឬ មិនច្បាស់លាស់នៅប្រទេសទាំងនោះក៏តែងជះឥទ្ធិពលមកប្រទេសយើងដែរ។ នៅប្រទេសបារាំង គេនិយមន័យពាក្យ "lexicologie" ដោយផ្អែកលើ "lexique" ថា ÷ "lexicologie" ជាវិជ្ជាដែលសិក្សាពី "lexique"។ តាមទម្លាប់ គេតែងប្រៀបធៀប "lexique" ទៅនិង "vocabulaire"។ គេថា "lexique" ជាសារព័នពាក្យ (ensemble des mots) ទាំងអស់របស់ភាសានីមួយៗ ហើយ "vocabulaire" ជាសារព័នពាក្យដែល អ្នកនិពន្ធម្នាក់ៗឬក្រុមអាជីវករនីមួយៗបាន/ត្រូវប្រើ។ ជួនកាល គេប្រទះការប្រើប្រាស់ពាក្យទាំងពីរនេះក្នុងន័យប្រហែលគ្នា ដូច "lexique de l'aviation" ឬ "vocabulaire de l'aviation", "lexique des termes médicaux" ឬ "vocabulaire médical" ជាដើម។

ក្នុងភាសាវិទ្យា "lexicologie"ជាវិជ្ជាដែលសិក្សាពី "lexique" ហើយ ដែលជាជាក់ស្ដែងទៅទៀត វាជាវិជ្ជាដែលសិក្សាពីវិធីបង្កើតពាក្យ រីឯ "étude de vocabulaire" វាជាវិជ្ជាដែលសិក្សាពីសារព័នពាក្យ តាមឯកទេស តាមជំនាញនីមួយៗ។ តាមរយៈ "vocabulaire" គេអាចធ្វើវិភាគរកវិធីបង្កើតពាក្យដែលជាតួនាទីរបស់ "lexicologie"។ ម្យ៉ាងទៀត គួរកត់សម្គាល់ថា "dictionnaire" (វចនានុក្រម) មានវិស័យទូលំទូលាយជាង "lexique" ដែលខ្មែរយើងប្រែថា សទ្ទានុក្រម។ បើយើងប្រែ

"lexicologie" ថា "វចនស័ព្ទវិទ្យា" គេនឹងយល់ថា វិជ្ជានេះសិក្សាពី "វចនស័ព្ទ" (lexèmes) ដែលជាការភាន់ច្រឡំ : វចនស័ព្ទទាំងប៉ុន្មាន គ្រាន់តែជាអនុប្រព័ន្ធមួយ ក្នុងចំណោម "មូលស័ព្ទ" (monèmes) ទាំងអស់ ដែលជាប្រព័ន្ធយ៉ាងទូលំទូលាយ និង ដែលចែកជា "វចនស័ព្ទ" មួយចំណែក និង "រូបស័ព្ទ" (morphèmes) មួយចំណែកទៀត ។ "lexicologie" មិនមែនវិជ្ជាសិក្សាតែពី "lexèmes" (វចនស័ព្ទ) ទេ តែជាវិជ្ជា ដែលសិក្សាពី "lexique" ដែលមាន "lexèmes" ផង និង "morphèmes" ផង : ដូច្នេះគប្បីយើងប្រែថា "វចនវិទ្យា" វិញ (ឬ ស័ព្ទវិទ្យា) ពីព្រោះ វចនស័ព្ទវិទ្យា គឺជាវិជ្ជាដែលគេអាចហៅថា "★ lexémologie" ទៅវិញទេ ។

## ៤ - **វាក្យស័ព្ទវិទ្យា** ("lexistique")[២១]

បារាំងឥតមានពាក្យពិសេសសំរាប់សម្គាល់វិជ្ជាដែលសិក្សាពី "vocabulaire" ទេ គេគ្រាន់តែប្រើវិញ្ញត្តិ[២២] (expression) ថា "étude de vocabulaire" ។ ពាក្យ "lexistique" ជាពាក្យថ្មីស្នើចេញពីសង្គមភាសាវិទ្យា ។ "Lexistique" ជាសម្រង់សារព័នពាក្យដែលគេអាចធ្វើការវិភាគអោយចេញជា "lexicologie" ដែលជាវិធីបង្កើតពាក្យ ឬ វចនវិទ្យា/ស័ព្ទវិទ្យា ដូច យើងបានឃើញរួចមកហើយ ។

## ៥ - **វចនាលេខនី**[២៣] (lexicographie).

វចនាលេខនី (ដែលយើងប្រែចេញពី "lexicographie") ជាវិធីធ្វើវចនានុក្រម ។ បើយើងធ្វើវចនានុក្រមដោយយកលំនាំតាមវចនានុក្រមណាមួយ ដែលមានមកស្រាប់ យើងក៏អាចធ្វើវចនានុក្រមរបស់យើងបានដែរ ប៉ុន្តែ វចនានុក្រមបារាំងដែលមានអ្នកធ្វើ/ក្រុមអ្នកធ្វើជាច្រើននាក់/ច្រើនក្រុមផ្សេងៗគ្នានោះ

---

២១ : យើងបានឃើញថា ក្នុងភាសាបារាំង ពាក្យ "lexique" និង ពាក្យ "vocabulaire" ត្រូវគេប្រើប្លែកគ្នាផងគ្នាផង និងដូចគ្នាផងតាមកាលៈទេសៈ ។ ចំពោះវិជ្ជាវិញ គេមានពាក្យទោល "lexicologie" (< lexique) និង កន្សោមពាក្យ "Etude du vocabulaire" (< vocabulaire) ។ បើយើងចង់ចៀសកន្សោមពាក្យយើងអាចផ្អែកលើ "vocabulaire" ឬ លើ "lexique" ហើយ យើងអាចបាន "vocabularistique" ឬ "lexistique" ហើយ យើងឃើញថា "vocabularistique" នៅជិត "Etude du vocabulaire" ជាងផង និង អាចឱ្យការបែងចែកមានបន្លែកច្បាស់លាស់ផង ("vocabularistique" ប្លែកឆ្ងាយពី "lexicologie") ប៉ុន្តែ "lexistique" ស្រួលប្រើជាង ។

២២ : ពាក្យ "វិញ្ញត្តិ" នេះមាននៅក្នុងវចនានុក្រម បារាំង-ខ្មែរ របស់លោក តិប យក់ និង ថាវ គន្ធ ។

២៣ : ខ្ញុំខ្ចីធាតុ "លេខ" នេះពីលោក កេង វ៉ាន់សាក់ (ដូចក្នុងពាក្យ "អង្គលីលេខ") ដើម្បីប្រែធាតុ "graphie" បារាំង (យកពី មូលភាព នៃការបង្កើតពាក្យថ្មី រោងពុម្ព ទេព បណ្ណាគាររស្មីកម្ពុជា ឆ្នាំ១៩៦៤ ទំព័រ៣១២) ។ យើងអាច ប្រែ "lexicographie" ថា "វចនានុក្រមវិទ្យា" ប៉ុន្តែ ពាក្យបារាំងទាំងប៉ុន្មាន ដែលមាន "-graphie" នៅខាងចុង ត្រូវប្រែចេញជាពាក្យខ្មែរ ដែលមាន "-វិទ្យា" ផង "-សាស្ត្រ" ផង,... នៅខាងចុង ហើយ ពាក្យទាំងនោះមិនសម្គាល់វិជ្ជាទេ ដូច radiographie, dactylographie ជាដើម ។

ត្រូវគេសម្គាល់ឃើញថា វាមានគុណភាពខុសគ្នា ពីព្រោះ អ្នកខ្លះ/ក្រុមខ្លះបានអនុវត្តទ្រឹស្តីភាសាវិទ្យាទាន់សម័យក៏ផង (គេអនុវត្តតាមគំហើញថ្មីៗនៃការស្រាវជ្រាវ) ហើយ គេបានស្រាវជ្រាវនិងបានស្រង់ពាក្យច្រើនលើសគេ និង ព្រមទាំងបានវិភាគពាក្យទាំងនោះដោយល្អិតល្អន់ជាងគេក៏ផង (សូមមើលតារាងវិភាគន័យតា : តារាងទី៣ និង តារាងទី៤) ។

## គោលសំខាន់ៗ នៃ ន័យកម្មវិទ្យា

### ១ - **ឯកតាក្នុងន័យ** (unité de sens) :

កំណត់សម្គាល់ : បច្ចេកទេសសម្រាប់វិភាគន័យនិងគំនិត ដែលខ្ញុំអត្ថាធិប្បាយតទៅនេះ ត្រូវបានខ្ចីពីលោក ប៊ែរណា ប៉ូជេ (Bernard POTTIER) និងពីលោក ទុយតេសគុយ (M. TUTESCU, Précis de sémantique française, Klincksieck) ។

### ១.១- **ន័យតា**[២៤] (sème / component) **និង វិភាគន័យតា** (analyse sémique / componentielle) :

ភាសាវិទូអាមេរិកកាំងហៅថា "component" ចំណែកលោក ប៊ែរណា ប៉ូជេ វិញ គាត់ហៅថា "sème" ដែលយើងប្រែថា "ន័យតា" ។ ន័យតា គឺជាសញ្ញាណសមមូល (notion équivalente) នៃវចនវិទ្យាទៅនឹងសញ្ញាតាបន្លឺសូរ (trait articulatoire) ដែលគេវិភាគឃើញក្នុងស័ទ្ទតានៃស័ទ្ទតាវិទ្យា (ដូច : សញ្ញាតា "ខ្យល់បន្ទុះ/នាសិកជៈ/សិថិល/ធនិត,...) ។ ន័យតាគឺជាឯកតាអប្បបរិមានៅក្នុងន័យបញ្ញត្តិណាមួយ ។ សញ្ញាតា "humain", "mâle" & "adulte" ដែលបូកចូលគ្នាបានជាវចនស័ព្ទ "homme" គឺជាន័យតា ។

វិភាគន័យតា (analyse sémique/analyse componentielle) គឺជាការស្រាវជ្រាវរកន័យតា ។ ដោយសារន័យតា ភាសាវិទូបានវិភាគឃើញមីក្រូប្រព័ន្ធស័ព្ទសាស្ត្រ (micro-systèmes lexicaux) ឬ មីក្រូ-បរិវេណ.ស័ព្ទ-ន័យសាស្ត្រ (micro-champs lexico-sémantiques) ។

---

២៤ : សូមសាធារណជនជ្រាបថា ពាក្យដែលយើងបានខ្ចីពីភាសាបាលី/សំស្ក្រឹតមិនត្រូវបានគេរក្សាន័យដើមទាំងអស់ទេ ហើយការផ្គុំធាតុ/ពាក្យដែលមានកំណើតបាលី/សំស្ក្រឹតក៏មិនត្រូវបានគេគោរពតាមវេយ្យាករណ៍បាលី/ សំស្ក្រឹតទាំងស្រុងដែរ ។ ម្យ៉ាងទៀត យើងបានដឹងហើយថា ចំណងរវាងន័យករនឹងន័យបញ្ញត្តិជាចំណងអាជ្ញាភាព (អាជ្ញាធិបតី) ។ បើពាក្យ "ន័យតា" មិនច្រឡំនឹងពាក្យណាមួយផ្សេងទៀតក្នុងភាសាខ្មែរទេ គប្បីយើងទទួលយកពាក្យនេះក្នុងន័យដែលត្រូវបានកំណត់ខាងលើនេះ ផងទៅ ។

ចំពោះគ្រឿងសង្ហារឹមនីមួយៗ ក្នុងចំណោមគ្រឿងសង្ហារឹមទាំងប៉ុន្មានដែលផ្ដុំជាមីក្រូ-បរិវេណ "អាសនៈ" វចនានុក្រមបារាំងមួយចំនួនបានកំណត់និយមន័យផ្អែកលើន័យតា (ដោយមិនបញ្ចេញឈ្មោះ) ដូចខាងក្រោមនេះ :

| វចនានុក្រម / វត្ថុ | Larousse | D.F.C. | Robert méthodique |
|---|---|---|---|
| កៅអី (chaise) | អាសនៈមានបង្អែក ឥតភ្នាក់ដៃ | អាសនៈមានបង្អែក ឥតភ្នាក់ដៃ | អាសនៈមានបង្អែក ឥតភ្នាក់ដៃ សំរាប់ មនុស្សតែម្នាក់ |
| កៅអីទ្រេត (fauteuil) | អាសនៈមានបង្អែក និង ភ្នាក់ដៃ | អាសនៈមានបង្អែក និង ភ្នាក់ដៃ | អាសនៈមានបង្អែក និង ភ្នាក់ដៃ សំរាប់មនុស្សម្នាក់ |
| ជើងតាំង (tabouret) | អាសនៈតូច មានជើង៤ ឥតបង្អែក និង ឥតភ្នាក់ដៃ | អាសនៈតូច ដែលតាមធម្មតា មានជើង៤ គ្មានបង្អែក និង គ្មានភ្នាក់ដៃទេ | អាសនៈឥតភ្នាក់ដៃ ឥតបង្អែក និង មានជើង |
| កៅអីទ្រេតវែង (canapé) | អាសនៈវែង មានបង្អែក សំរាប់មនុស្សច្រើននាក់ | អាសនៈវែង មានបង្អែក និង មានភ្នាក់ដៃ ដែលមានមនុស្សច្រើនអាចអង្គុយបាននិងអាចដេកបាន | អាសនៈវែង មានបង្អែក មនុស្សច្រើនអាចអង្គុយរួមគ្នាបានឬអាចប្រើប្រាស់ជាគ្រែសំរាប់សំរាកក៏បាន |
| កៅអីខ្នើយ (pouf) | អាសនៈមួយបែបញាត់គរ / រោមសត្វ ទាប ហើយទូលាយ | អាសនៈទាប ធ្វើពីស្បែកឬក្រណាត់ ដែលមានញាត់គរឬរោមសត្វ | អាសនៈទាប/ទ្រនាប់ធំ ញាត់គរ/ រោមសត្វ ឥតជើង |

<u>តារាង ៣</u>

យើងសង្កេតឃើញថា វចនានុក្រមទាំងបីសុទ្ធតែភ្លេចបញ្ជាក់ពីន័យតាថា "ទ្រនាប់ទន់" របស់កៅអីទ្រេត និង របស់កៅអីទ្រេតវែង។ ម្យ៉ាងទៀត ន័យតាខ្លះមានក្នុងវចនានុក្រមនេះ ឥតមានក្នុងវចនានុក្រមនោះ : ឧ. សម្រាប់កៅអីទ្រេតវែង ន័យតា "ភ្នាក់ដៃ" ឥតមានក្នុង វចនានុក្រម Larousse & វចនានុក្រម Robert méthodique ទេ។ ដោយស្រង់ន័យតាទាំងប៉ុន្មាន ដែលវចនានុក្រមទាំងបីបានផ្ដល់យើងក៏បានន័យតាជាអតិបរមា។ បែរណា ប៉ូជេ បានវិភាគឃើញន័យតា៦ប្រភេទ ដូចមានក្នុងតារាងវិភាគខាងក្រោមនេះ :

| ន័យតា / វចនស័ព្ទ | ន័យតា១ : សម្រាប់អង្គុយ | ន័យតា២ : មានជើង | ន័យតា៣ : សម្រាប់មនុស្សម្នាក់ | ន័យតា៤ : មានបង្អែក | ន័យតា៥ : មានភ្នាក់ដៃ | ន័យតា៦ : ធ្វើពីធាតុរឹង |
|---|---|---|---|---|---|---|
| កៅអី | + | + | + | + | - | + |
| កៅអីទ្រេត | + | + | + | + | + | + |
| ជើងតាំង | + | + | + | - | - | + |
| កៅអីទ្រេតវែង | + | + | - | + | + | + |
| កៅអីខ្នើយ | + | - | + | - | - | - |

តារាង ៤

**១.២ - អត្តន័យតា** (sème identificateur / suisème) **និង ឋានន្តរន័យតា** (sème classificateur / classème) :

គេអាចចែកន័យតាជាពីរពួក គឺ អត្តន័យតា និង ឋានន្តរន័យតា ។

**១.២.១ - អត្តន័យតា** (sui-sème) **:**

អត្តន័យតាជាន័យតាមួយបែបសម្រាប់សម្គាល់អត្តសញ្ញាណកម្ម (identlipcat) ក្រុមអត្តសញ្ញាណ-កម្មនេះត្រូវនឹងពាក្យ (identlipcat) ខ្ទីពី bolinlé(lagnenàa) នៃពាក្យណាមួយ[២៥] ហើយ ដែលលេចចេញពីបដិកម្ម (opposition) រវាងពាក្យនោះនិងពាក្យឯទៀត ប្រហាក់ប្រហែលគ្នានឹងនិយមន័យស្ដីពីសូរស័ព្ទភាសារបស់លោក ហ្គាញើប៉ាំង (Gagnepain) ដែលបានថា "សូរស័ព្ទភាសាជាទម្រង់ ហើយ ទម្រង់ជាសារព័ន្ធនៃធាតុមួយចំនួន (un ensemble d'éléments) ដែលក្នុងនោះធាតុនីមួយៗគឺជាអ្វីដែលមិនមែនធាតុឯទៀត" ។

**១.២.២ - ឋានន្តរន័យតា** (classème) **:**

ឋានន្តរន័យតាគឺជាន័យតា១បែប គឺជាសញ្ញាតាបរិបទ (trait contextuel) ដែលអាចឱ្យយើងស្គាល់លក្ខណៈសម្ព័ន្ធរបស់ពាក្យ ដូច :

- + animé : + ជីវិតភាព : (មានជីវិត),
- - animé : - ជីវិតភាព (ឥតជីវិត) ។

---

[២៥] : ក្នុងករណីនេះ ក្រុមពាក្យគឺជាពាក្យមួយចំនួន ដែលរួមគ្នាជាមីក្រូ-បរិវេណ ស័ព្ទ-ន័យសាស្ត្រ (micro-champs lexico-sémantique) ។

- + nombrabilité : + គណនីយភាព : ( រាប់បាន ដូច : នាឡិកាមួយ, នាឡិកាពីរ);
- - innombrabilité : -គណនីយភាព ( រាប់ឥតបាន ដូច : មេឃ/ខ្យល់[២៦], ... ) ។
- + transitivité : + កិរិយាសកម្ម ( ជាកិរិយាសកម្ម),
- - transitivité : - កិរិយាសកម្ម ( មិនមែនកិរិយាសកម្ម គឺកិរិយាអកម្ម);

គេអាចប្រើឋានន្តរន័យតា សម្រាប់សរសេររូបមន្តសម្គាល់លក្ខណៈសម្ព័ន្ធរបស់ពាក្យណាមួយ[២៧] ដូចលក្ខណៈសម្ព័ន្ធនៃកិរិយាស័ព្ទជាដើម ដូច :

- កិរិយាស័ព្ទ "ខ្លាច" ត្រូវការប្រធានដែលមានសញ្ញាតា "+ជីវិតភាព" និងកម្មបទដែលមានសញ្ញាតា "± ជីវិតភាព" ហើយ គេអាចសរសេររូបមន្តសម្គាល់លក្ខណៈសម្ពន្ធ័របស់កិរិយាសព្ទនេះ ដូចនេះ [(+ជីវិតភាព) —— (± ជីវិតភាព)] ។
- កិរិយាស័ព្ទ "សង់" ត្រូវមានប្រធានដែលមានសញ្ញាតា "+ជីវិតភាព" និង កម្មបទដែលមានសញ្ញាតា "-ជីវិតភាព" ហើយ គេអាចសរសេររូបមន្តសម្គាល់លក្ខណៈសម្ពន្ធ័របស់កិរិយាសព្ទនេះ ដូចនេះ [(+ជីវិតភាព) —— (-ជីវិតភាព)] ។

ឋានន្តរន័យតាបង្ហាញអោយឃើញថា ពាក្យនីមួយៗសុទ្ធតែត្រូវការលក្ខណៈសម្ព័ន្ធ ដើម្បីឱ្យន័យរបស់ខ្លួនលេចចេញគ្រប់ជ្រុងជ្រោយ ។

## **១.៧ - <u>បូរណន័យតា</u> (sémème) :**

បូរណន័យតាជាសារព័នសរុប (un ensemble uni) ដែលមានអត្ថន័យតាផង និង ឋានន្តរន័យតាផង ។ តាមលោក ហ្សង់ ឌុយប័រ[២៨] (Jean Dubois) កិរិយាស័ព្ទបារាំង savoir មានន័យតា៦ប្រភេទ ( ខ្លះជាអត្ថន័យតា ខ្លះទៀតជាឋានន្តរន័យតា) គឺ :

( ១) • + avoir ( ប្រើ "avoir" ជាកិរិយាជំនួយ)

( ២) • + transtivité : + កិរិយាសកម្ម

---

២៦ : លក្ខណៈ"គណនីយភាព" ដូចជាមិនសូវត្រូវចំពោះភាសាខ្មែរទេ ពីព្រោះ គេច្រើនយក ភ្នាប់ ( រាប់ > ភ្នាប់ = ឧបករណ៍សម្រាប់រាប់/សម្រាប់សម្គាល់ = classificateur , ដូច១នាក់/១ក្បាល/១គ្រឿង/១ប្រភេទ,...) មកផ្គុំជាមួយនាមស័ព្ទ ដែលអាចអោយគេរាប់អ្វីៗបានស្ទើរតែទាំងអស់ ។

២៧ : លក្ខណៈសម្ព័ន្ធ គឺសញ្ញាតាដែលបញ្ជាក់ថា នាមស័ព្ទណាអាចប្រើជាកម្មរងជាមួយកិរិយាស័ព្ទក្រុមណា ហើយមិនអាចប្រើបានជាមួយកិរិយាស័ព្ទក្រុមណា ជាដើម ព្រមទាំងអោយដឹងថា វាត្រូវប្រើផ្ទាល់ជាមួយកិរិយាស័ព្ទ ឬក៏ត្រូវមាននិបាតស័ព្ទជាឧបករណ៍សម្រាប់ភ្ជាប់ ។

២៨ : Jean Dubois & Françoise Dubois-Charlier, Eléments de linguistique française : la syntaxe, Larousse 1970, p.91 .

(៣) • + duratif : ចិរភាព

(៤) • + rèsultalif : + លទ្ធផលភាព

(៥) • + sujet animé : + ប្រធានជាមនុស្ស/សត្វ (ដែលមានជីវិត),

(៦) • - complément animé : - កម្មបទជាមនុស្ស/សត្វ (ផ្ទុយពី កម្មបទមនុស្ស/សត្វ) ។

សញ្ញាតា (៥) & (៦)ជាអត្ថន័យតា ពីព្រោះវាជាន័យតាឥតទាក់ទងនឹងលក្ខណៈសម្ព័ន្ធរបស់កិរិយាស័ព្ទ savoir ទេ។ សញ្ញាតាពី (១) ដល់ (៤) ជាឋានន្តរន័យតា ពីព្រោះ វាបង្ហាញលក្ខណៈសម្ព័ន្ធរបស់កិរិយាស័ព្ទ savoir ។

<u>ពន្យល់</u> :

(១) - <u>លទ្ធផលភាព</u> : កិរិយាស័ព្ទ savoir មានសញ្ញាតា "លទ្ធផលភាព" ពីព្រោះ savoir ជាលទ្ធផលបានពី apprendre ។

(២) - <u>ចិរភាព</u> : កិរិយាស័ព្ទនេះ (ផ្ទុយពី arriver, commencer ជាដើម) មានសុពលភាពយូរអង្វែង (គេប្រើ "je savais" មិនមែន "j'ai su" ទេ) ។

(៣) - <u>កម្មវង្សវត្ថុសភាព</u> : កិរិយាស័ព្ទនេះអាចទទួលយកកម្មវង្សវត្ថុ គឺជា (ស)កម្មកិរិយា ។

(៤) - <u>វិភត្តិនីយកម្មដោយជំនួយ "avoir"</u> = កិរិយាស័ព្ទនេះប្រើកិរិយាស័ព្ទ "avoir"ជាជំនួយក្នុងវិភត្តិនីយកម្ម (conjugaison)[២៩] ។

(៥) - <u>ប្រធាន [+ជីវិតភាព]</u> = កិរិយាស័ព្ទនេះត្រូវមានប្រធានជាមនុស្ស ឬ សត្វដែលមានជីវិត (វត្ថុមិនអាចចេះ (savoir)អ្វីៗទេ) ។

(៦) - <u>កម្មវង្ស [-ជីវិតភាព]</u> = កិរិយាស័ព្ទនេះត្រូវមានកម្មវង្សជាអ្វីដែលគ្មានជីវិត (គេចេះវិជ្ជាអ្វីមួយ តែគេមិនអាចចេះ*ឰសុខ/ចេះ*ក្របី ទេ) ។

## ១.៤ - <u>អតិបូរណន័យតា</u> (archi-sémème) :

ដើម្បីយល់ពីអតិបូរណន័យតា យើងផ្អែកលើបញ្ញត្តិអតិស័ទ្ទតា : ក្នុងភាសាអាល្លឺម៉ង់ ពាក្យ "rat" (= ដំបូន្មាន) និង ពាក្យ"rad"(= កង់) ត្រូវម្ចាស់ភាសាអានដូចគ្នា គឺព្យញ្ជនៈ ខាងចុង ([t] & [d]) នៃពាក្យទាំងពីរមានលក្ខណៈមិនច្បាស់ជាឃោសៈឬជាអឃោសៈទេ : ស័ទ្ទតាវិទូបានសម្រេចហៅបាតុភាពបែបនេះថា "អព្យាក្រឹតកម្ម" (neutralisation) : សញ្ញាតា "ឃោសៈ" និង សញ្ញាតា "អឃោសៈ" បានក្លាយជាសញ្ញាតាអព្យាក្រឹត ដែលគេកត់ សម្គាល់បែបនេះ ÷ [± ឃោសៈ] ហើយបាតុភាពនៃអព្យាក្រិតកម្មបាននាំមកនូវស័ទ្ទតាមួយ បែបដែលគ្របដណ្តប់លើឃោសៈផងនិងអឃោសៈផង

[២៩] : គប្បីយើងប្រែ"វិភត្តិនីយកម្ម" ថា "conjugaison" ឬ ថា "déclinaison" តាមស្ថានការណ៍ ។

ហៅថា អតិស័ទ្ទតា (archiphonème) កត់ត្រាដោយអក្សរធំ / T / : ដូច្នេះ "rat" & "rad" ត្រូវទទួលការកត់ត្រារួមដូចនេះ / raT/ ។

អតិបូរណន័យតាមានលក្ខណៈដូច អតិស័ទ្ទតា ហើយ យើងគ្រាន់តែចាំកុំភ្លេចថា ស័ទ្ទតាឋិតនៅក្នុងសន្ទិយោគជាន់ទី២ (2ᵉ articulation) រីឯវចនស័ព្ទវិញ វាឋិតនៅក្នុងសន្ទិយោគ ជាន់ទី១ គឺមានន័យករផង និង ន័យបញ្ញត្តិផង :

- បូរណន័យតា គឺជាសារព័ននៃន័យតាទាំងប៉ុន្មានរបស់ពាក្យណាមួយ/ក្រុមពាក្យណាមួយ ( អត្ថន័យតា + ឋានន្តរន័យតា) ។
- អតិបូរណន័យតា គឺជាន័យតាដែលក្រោយបាតុភាពអព្យាក្រិតកម្មនៃន័យតាឯទៀតៗបាន ក្លាយទៅជាន័យតារួមគ្របដណ្តប់លើន័យតាអព្យាក្រិតទាំងប៉ុន្មាន : ក្នុងតារាងលេខ៤ យើង សង្កេតឃើញថា ន័យតាពីទី២ទៅទី៦ បានទទួលសញ្ញា (+) ផង និង សញ្ញា ( –) ផង : [± មានជើង] , [± មាន បង្អែក] , ... ហើយ ន័យតាទី១ បានក្លាយទៅជាន័យតារួមគ្របបណ្តប់ទាំងលើកៅអី ទាំងលើជើងតាំង -ល- ( ទោះកៅអីក្តី ឬ ជើងតាំងក្តីក៏វាជាឧបករណ៍ "សម្រាប់អង្គុយ"ដែរ) វាជា <u>អតិបូរណន័យតា</u>។

## ១.៥ – <u>អតិវចនស័ព្ទ</u> (archi-lexème) :

តារាងលេខ៤បានបង្ហាញអោយឃើញថា អតិបូរណន័យតា គឺ "សម្រាប់អង្គុយ" ហើយ វចនស័ព្ទដែលស្របនឹង "សម្រាប់អង្គុយ" គឺ "អាសនៈ" ។ វចនស័ព្ទ"អាសនៈ"ទាក់ទងនឹងអតិបូរណន័យតា : គឺជាអតិវចនស័ព្ទ ។

<u>កំណត់សម្គាល់</u> : (១) - អតិវចនស័ព្ទមានន័យករផង និង ន័យបញ្ញត្តិផង រីឯអតិបូរណន័យតា វាជាបំណែកន័យជាកម្មេចន័យនៅក្នុងន័យបញ្ញត្តិ ។

(២) - ក្នុងករណីខ្លះ បញ្ញត្តិ "អតិន័យតា" ឥតមានអតិវចនស័ព្ទជាទម្រ<u>ទេ</u> ពីព្រោះអតិបូរណន័យតាជាលទ្ធផលនៃការវិភាគរកន័យតាតាមបញ្ញាញាណ ដោយឥតគិតពីការខ្វះចន្លោះនៃមីក្រូ-ប្រព័ន្ធស័ព្ទសាស្ត្រទេ : ឧ. អតិបូរណន័យតា"សម្រាប់អង្គុយ" មិនទាន់មានអតិវចនស័ព្ទជាទម្រទេកាលពីប៉ុន្មានសិបឆ្នាំមុន ពីព្រោះ ពាក្យ "អាសនៈ" ដែលសម្គាល់តែកន្លែងគង់កល់ព្រះពុទ្ធរូប ទើបតែត្រូវបានគណៈកម្មការវប្បធម៌តម្រូវអោយសម្គាល់ឧបករណ៍សម្រាប់អង្គុយ ក្នុងរវាងឆ្នាំ១៩៥០ ។

## ២ – <u>ទំនាក់ទំនងរវាងន័យ</u> (Relations sémantiques) :

## ២.១ – <u>វិចារណកម្មទូទៅ</u>

គេតែងសង្កេតឃើញថា ក្នុងករណីខ្លះមានន័យបញ្ញត្តិជាច្រើនសម្រាប់ន័យករតែមួយ ហើយ គេចាត់ទុកថាជាសទិសស័ព្ទ (homonyme) ឬ ថាជាពហុន័យ (polysens) ទៅតាមករណី :

- គេទុកជាសទិសស័ព្ទ កាលណាន័យបញ្ញត្តិទាំងប៉ុន្មានឃ្លាតដាច់ពីគ្នាជ្រះស្រឡះ ដូច ÷

  - ក្នុងភាសាខ្មែរ : ទ្រ (ឧបករណ៍ភ្លេង) និងទ្រ (កិរិយាស័ព្ទដែលមានន័យថា "កាន់ទប់ពីក្រោម/ដាក់គល់ពីក្រោម") ។

  - ក្នុងភាសាបារាំង : vol (d'oiseau) & vol (d'un voleur) ។

- គេទុកជាពហុន័យ កាលណាន័យបញ្ញត្តិទាំងប៉ុន្មានមិនទាន់ឃ្លាតដាច់គ្នាជ្រះស្រឡះ ដូច ÷

  - ក្នុងភាសាខ្មែរ ÷ បិណ្ឌ : កាន់បិណ្ឌ/ដាក់បិណ្ឌ/បិណ្ឌបាត/បិណ្ឌមួយ/បិណ្ឌពីរ,...

  - ក្នុងភាសាបារាំង : fille (féminin de "fils") & fille (féminin de "garçon") ។

ផ្ទុយទៅវិញ ក្នុងករណីខ្លះ មានន័យបញ្ញត្តិតែមួយសម្រាប់ន័យករជាច្រើន : គេទុកករណីនេះជាវេវចនស័ព្ទ (synonyme) ដូច ÷ ប្ដី & ស្វាមី/ប្រពន្ធ & ភរិយា។ ប៉ុន្តែ គួរយើងកត់សម្គាល់ថា ក្នុងករណីជាច្រើនវេវចនស័ព្ទឥតមានន័យតាត្រូវគ្នា១០០%ទេ : ប្ដីនិងស្វាមីមិនអាចប្រើជំនួសគ្នាបានរាល់កាលៈ-ទេសៈឡើយ ។

ម៉្យាងទៀត ទំនាក់ទំនងរវាងន័យអាចជាស្ថានភាពអន្តរកម្ម (intersection) ឬកជាមួយបដិកម្ម (opposition) ឬ ឬកជាមួយអន្តេវេណ (inclusion) រវាងន័យបញ្ញត្តិពីរ[៣០] ឬ រវាងន័យបញ្ញត្តិមួយនិងន័យបញ្ញត្តិមួយក្រុម :

- ក្នុងករណីទី១ គេចាត់ទុកថាជាបដិស័ព្ទ (antonyme) ដូច ÷ ចូល ~ ចេញ ។

- ក្នុងករណីទី២ គេចាត់ទុកថាជាអនុស័ព្ទ (hyponyme) ដូច ÷ "ឡាន" និង "ម៉ូតូ" ដែលជាអនុស័ព្ទរបស់ "យាន" ("យាន" ជាមហាស័ព្ទ (hyperonyme) ចំពោះ"ឡាន" និង "ម៉ូតូ") ។

រូបសញ្ញាខាងក្រោមនេះបង្ហាញអោយឃើញជាក់ស្តែងនូវករណី "បដិស័ព្ទ" និង ករណី "អនុស័ព្ទ" ។

---

៣០ : "ន័យបញ្ញត្តិពីរ" ត្រូវមាន "ពាក្យពីរម៉ាត់" ដែរ ពីព្រោះ ពាក្យមួយមានន័យបញ្ញត្តិមួយ ។

ករណីទី១ :




រូបសញ្ញា ៧ ( បង្ហាញបដិស័ព្ទភាព)

ករណីទី២ :




រូបសញ្ញា ៨ ( បង្ហាញអនុស័ព្ទភាព)

ការសង្កេត : យើងអាចយល់បានថា ន័យតាដែលនៅក្រៅបរិវេណជំនួបកត់សម្គាល់ស្ថានភាពពីរប្លែកគ្នា :

- ក្នុងរូបសញ្ញា៧ វាសម្គាល់បដិស័ព្ទភាព ពីព្រោះ ន័យតានីមួយៗសម្គាល់ចលនាផ្ទុយគ្នា។
- ក្នុងរូបសញ្ញា៨ វាសម្គាល់អនុស័ព្ទភាព ពីព្រោះ ន័យតានីមួយៗឥតសម្គាល់អ្វីដែលមានភាពផ្ទុយគ្នាទេ : វាគ្រាន់តែប្លែកគ្នាប៉ុណ្ណោះ ។

## ២.២ - សិក្សាលំអិតអំពីប្រភេទនិមួយៗនៃទំនាក់ទំនងរវាងន័យ :

### ២.២.១ - សទិសស័ព្ទ និង ពហុន័យ (homonyme & polysens) :

មានតែបច្ចេកស័ព្ទទេ ដែលអាចចៀសផុតពីពហុន័យតា ដោយសារពាក្យនោះជាពាក្យពិសេសថ្មីថ្មែង (ឧ.ស័ទ្ទតា/ន័យតា,...) ឬ ដោយសារមានការកំណត់ន័យពិសេសថ្មីថ្មែងឱ្យពាក្យណាមួយ ពិតមែនតែពាក្យនោះមានមកស្រាប់ (ឧ. ក្នុង "សូរវិទ្យា" "សូរ"មានន័យច្បាស់ក្នុងរង្វង់តូចជាងន័យទូទៅ ដែលគេប្រើក្នុងករណីធម្មតាហើយដែលគេច្រើនផ្គុំជាមួយ "សម្លេង" ថា "សូរសម្លេង") ។

ក្រៅពីករណីខាងលើ ពាក្យតែងតែមានពហុន័យ តិចឬច្រើន។ តាមគោលការណ៍ (តាមទ្រឹស្តី) សទិសស័ព្ទពីរអង្គមានន័យបញ្ញត្តិដាច់គ្នាស្រឡះ ហើយផ្ទុយទៅវិញ រវាងពហុន័យ ផ្សេងៗរបស់ពាក្យណា

មួយ (ពាក្យតែមួយ) គេសង្កេតឃើញថា ន័យទាំងនោះមានន័យតាមួយចំនួនដែលជាន័យតារួម ។ ប៉ុន្តែតាមជាក់ស្តែង គេឥតមានលក្ខណៈវិនិច្ឆ័យអ្វី ដើម្បីជួយញែក បន្លែកបែបនេះទេ ដូច្នេះហើយ *វចនាលេខវិទូ* (lexicographe) តែងតែធ្វើជម្រើសអញ្ញថាភាព (choix subjectif) ដូចមានឧទាហរណ៍ទាក់ទងនឹងពាក្យបារាំង "bureau" តាមរយៈវចនានុក្រមពីរប្លែកគ្នា គឺវចនានុក្រម D.F.C. និង វចនានុក្រម Robert Méthodique :

- វចនានុក្រមD.F.C. បានទុក "bureau" ជាមេពាក្យពីរដាច់គ្នា : មេពាក្យទី១ សម្រាប់ន័យថា "តុ/បន្ទប់ដែលគេដាក់ bureau" ឯមេពាក្យទី២វិញ វចនាលេខវិទូ សំដៅសេចក្តីថា "គ្រឹះស្ថាននៃសេវាពាណិជ្ជកម្ម ឬ ឧស្សាហកម្ម/បេឡា នៃរោងល្ខោន/បុគ្គលិកនានានៃគ្រឹះស្ថានណាមួយ"... ។

- វចនានុក្រម Robert Méthodique បានទុក "bureau" ថាជាមេពាក្យ តែមួយ ។

វចនានុក្រម D.F.C. បានទុកពាក្យ "bureau" ថាជាសទិសស័ព្ទពីរអង្គ ចំណែកអ្នកធ្វើវចនានុក្រម Robert Méthodique វិញ គេទុកពាក្យដដែលនេះថាជាពាក្យតែមួយម៉ាត់ ដែលមានន័យច្រើន គឺពហុន័យ ។

### ២.២.១.១ - សទិសស័ព្ទ

ក្នុងករណីនេះ គេត្រូវបែងចែករវាងសទិសសូរ (homophone)និងសទិសលេខនី (homographe) ។ សទិសសូរ គឺជាសទិសស័ព្ទពីរអង្គដែលមានសូរដូចគ្នា (អក្ខរាវិរុទ្ធខុសគ្នា ឬ ដូចគ្នា) ដូច ÷ គុន & គុណ ។ សទិសលេខនីគឺជាសទិសស័ព្ទពីរអង្គដែលមានអក្ខរាវិរុទ្ធដូចគ្នា (សូរខុសគ្នា ឬ ដូចគ្នា) ដូច ÷ លិច [ឡិច] (ខាងលិច) & លិច [លិច] (កិរិយាស័ព្ទ) ។ ជួនកាល សទិសស័ព្ទជាសទិសសូរផងនិងជាសទិសលេខនីផង ដូច ÷ ខ្ញុំ (សព្វនាម) និង ខ្ញុំ[៣១] (នាមស័ព្ទ មានន័យថា "បាវព្រាវ") ។

សទិសស័ព្ទអាចមានន័យពាំត្រណោត ក្នុងករណីដែលពាក្យទាំងពីរនៅក្នុងប្រភេទពាក្យជាមួយគ្នា ហើយមានទីតាំងដូចគ្នាក្នុងឃ្លាដូច ÷ បិតស្រា & បិទទ្វារ ។ ករណីនេះជាបញ្ហា <u>ពាំត្រណោតស័ព្ទសាស្ត្រ</u>

---

៣១: ពាក្យ "ខ្ញុំ" ទាំងពីរបែបខាងលើនេះ ពីដើមឡើយ ជាពាក្យតែមួយ ។ កាលពីដើម ពាក្យ "ខ្ញុំ" ប្រើសម្រាប់តែអ្នកតូចតាចទេ ។ អ្នកធំ/អ្នកមានវ័យចាស់តែងប្រើពាក្យ "អញ" ។ ឥឡូវនេះ ពាក្យ "អញ" មិនពិរោះស្តាប់ទេ : គេ<u>ច្រើន</u>ប្រើ "យើង" ជំនួសវិញ ។

(ambiguité lexicale)។ ម្យ៉ាងទៀត គប្បីយើងកត់សម្គាល់ថា បញ្ហាពាំត្រណោតអាចជាបញ្ហា ពាំត្រណោតសម្ព័ន្ធសាស្ត្រផងដែរ (ambiguité syntaxique) :

- ឧទាហរណ៍ជាបារាំង : "je préfère le café au lait" ដែលមានន័យពីរ :

(១) - គឺ "ខ្ញុំចូលចិត្តកាហ្វេទឹកដោះគោ" ;

(២) - គឺ "ខ្ញុំជ្រើសយកកាហ្វេឥត យកទឹកដោះគោទេ"។

- ឧទាហរណ៍ជាខ្មែរ : "ខ្ញុំចូលចិត្តតែទឹកដោះគោ" ឃ្លានេះក៏មានន័យពាំត្រណោតដែរ :

(១) - ខ្ញុំផឹកតែ (ទឹកតែ) ដែលលាយជាមួយទឹកដោះគោ ;

(២) - ខ្ញុំផឹកទឹកដោះគោ ឥតផឹកអ្វីផ្សេងទេ។

នៅក្នុងភាសាខ្លះ គេសង្កេតឃើញមានសទិសស័ព្ទភាពរវាងមូលបទ (homonymie grammaticale) ដូច :

- បុព្វបទ /រ-/ ក្នុងភាសាខ្មែរដែលជាបុព្វបទសម្គាល់កិរិយាស័ព្ទអត្តផលផង (verbe à action réfléchie) ដូច ÷ រលត់ (< លត់) និង ជាបុព្វបទសម្គាល់សភាពច្រូងច្រាងផង ដូច : រយោង (< យោង)។

- បច្ឆិមបទ /-eur/ ក្នុងភាសាបារាំង ដែលសម្រាប់បង្កើតនាមភ្នាក់ងារចេញពី កិរិយាស័ព្ទផង : Vendeur (< v. vendre) និងសម្រាប់បង្កើតនាមសម្គាល់ គុណភាពផង : laideur (< adj. laid)។

ការសិក្សាតាមអ័ក្សរយៈកាល (axe diachronique) បានបង្ហាញអោយឃើញថា សទិសស័ព្ទ មានពីរបែប :

- ១បែបជាលទ្ធផលនៃការវិវឌ្ឍសូរដែលជំរុញសូរពីរប្លែកគ្នាអោយដូចគ្នា។ ពាក្យបារាំងមួយចំនួនមានជាតិស័ព្ទខុសគ្នា តែការវិវឌ្ឍសូរបានធ្វើសូរឱ្យដូចគ្នា ដូចតទៅ :

  - sanus > sain [sɛ̃] ;
  - sanctus > saint [sɛ̃] ;
  - sinus > sein [sɛ̃] .

- ១បែបទៀតជាលទ្ធផលនៃបំណែក( ការបែក)ស័ព្ទ ដែលបានធ្វើអោយស័ព្ទមួយ បែកជាពីរ ដូចសទិសស័ព្ទបារាំង "vol" ដែលមានន័យពីរដាច់គ្នា គឺ (១) = ការលួច & (២) =ការហើរ ។ កាលដំបូងឡើយ ពាក្យនេះមានរូបតែមួយ ផង និង មានន័យតែមួយផង ។

**២.២.១.២ - ពហុន័យ**

ពាក្យបារាំងដូចពាក្យ "tilleul" មានន័យជាច្រើន ប៉ុន្តែ ន័យទាំងអស់សុទ្ធតែត្រូវភ្ជាប់ទៅប្រភពតែមួយ គឺប្រភេទឈើឈ្មោះ "tilleul" ។ ន័យផ្សេងៗមានដូចខាងក្រោម :

- មានន័យជាដើមឈើ : Elle dormait à l'ombre d'un tilleul.
- មានន័យជាឈើ : Ma grand-mère avait une table en tilleul.
- មានន័យជាផ្កា : Je voudrais un paquet de tilleul.
- មានន័យជាទឹកថ្នាំ : Tous les soirs, elle prend son tilleul.

ពហុន័យជាបាតុភូតចៀសមិនផុត : អោយតែគេប្រើពាក្យណាមួយ ពាក្យនោះនឹងមានន័យប្លែកបន្តិចបន្តួចតាមករណីស្ទើរតែរាល់ដង ។ ប៉ុន្តែ បាតុភូតនេះមិនរំខានដល់ទំនាក់ទំនងរវាងអ្នកនិយាយគ្នា (អន្តរជន)ទេ ពីព្រោះ ផ្ទុយទៅវិញ គឺន័យបរិបទ (sens contextuel) ឬ ន័យក្នុងឈ្នះបែបនេះ ហើយដែលធ្វើឱ្យយើងយល់ច្បាស់ពីស្ថានភាពណាមួយ : ន័យទូទៅ (ន័យកម្ម) ក្រៅបរិបទទុកយើងឱ្យនៅក្នុងស្ថានភាពមិនច្បាស់លាស់ ។

**២.២.២ - វេវចនស័ព្ទ (synonyme)**

ពាក្យពីរម៉ាត់ ឬ វាចាវិលាស (locution)[៣២] ពីរម៉ាត់ជាវេវចនស័ព្ទនឹងគ្នា កាលណាពាក្យ/វាចាវិលាសនោះមានប្រភេទដូចគ្នានិងអាចជំនួសគ្នាបានក្នុងឈ្នះ ដោយឥតបណ្ដាលឱ្យឈ្នះមានន័យផ្សេង ។ តាមធម្មតា ពាក្យពីរម៉ាត់ ដែលជាវេវចនស័ព្ទនឹងគ្នាមិនមានន័យដូចគ្នាបេះបិទទេ : គេអាចប្រើវាជំនួសគ្នាបានតែក្នុងករណីខ្លះ ឬ ក៏វាជំនួសគ្នាបានតែសណ្ឋានភាសា (registres) មានកម្រិតខុសគ្នា :

(១) - ឧទាហរណ៍បង្ហាញការជំនួសគ្នាមិនបានគ្រប់កាលៈទេសៈ ÷

- le bec aigu --> le bec pointu : "pointu" & "aigu" ជំនួសគ្នាបាន ។

---

[៣២] : ពាក្យ "វាចាវិលាស" នេះមានក្នុងវចនានុក្រមបារាំង-ខ្មែររបស់លោក តិប យក់ និង ថាវ គន្ធ ។

-le son aigu --> *le son pointu : "aigu" & "pointu"
ជំនួសគ្នាឥតបានទេ។

(២) - ឧទាហរណ៍បង្ហាញការប្តូរសណ្ឋានភាសា ÷

- manque de chance (សណ្ឋានខ្ពស់) ≠ manque de pot (សណ្ឋានទាប) ។

- ស្វាមី (សណ្ឋានខ្ពស់) ≠ ប្តី (សណ្ឋានធម្មតា)

គេអាចជំនួសពាក្យទាំងអស់ដោយប្រើនិយមន័យជាបរិព័ន្ធ/បរៈឃ្លា (périphrase) ។ ក្នុងភាសាបារាំង គេហៅបរិព័ន្ធសម្រាប់បិទបាំងអ្វីដែលមិនល្អស្តាប់ថា "euphémisme" ដែលយើងអាចប្រែថា "វិសាលស័ព្ទ" ដូច ÷ rendre l'âme = ទៅបរលោក , avoir des rapports sexuels = រួមរក្ស ។

ក្នុងភាសាបារាំងដដែល គេមានពាក្យមួយទៀតហៅថា "litote" ដែលសម្គាល់បរិព័ន្ធសម្រាប់បង្អើបគំនិតអោយអ្នកឯទៀតយល់ដោយមិនចង់និយាយចំ ហើយ ដែលយើងអាចប្រែ ថា "សម្តីបង្អើប" ដូច : Il ne m'est pas antipathique = គាត់មិនមែនជាមនុស្សគួរឱ្យស្អប់ទេ = ខ្ញុំស្រឡាញ់គាត់ ។

**២.២.៣ - បដិស័ព្ទ** (antonyme)

តាមភាសាវិទូមួយចំនួន[៣៣] ន័យរបស់ពាក្យ "antonyme" (ដែលយើងប្រែថា "បដិស័ព្ទ") មានព្រំដែនមិនជាក់លាក់ : វាសម្គាល់បដិកម្ម (opposition) ពិតប្រាកដ (រវាង បដិសព្ទពិតប្រាកដ) ផង សម្គាល់ប្រតិភាព[៣៤] (réciprocité) ផង និង ភាពដៃគូនឹងគ្នា (com- plémentarité) ផង ។

(១) - បដិស័ព្ទភាពពិតប្រាកដមានជំនឿន (progression) លើមាត្រដ្ឋាន (échelle) ជាមួយគ្នា ដូច "តូច" និង "ធំ" ដែលនៅលើមាត្រដ្ឋាន "ដងខ្លួន" : អ្វីដែលមិនធំ មិនប្រាកដជាតូចទេ : វាអាចជាមធ្យម ។ គឺក្នុងករណីនេះហើយដែលគេអាចប្រើវិសេសគុណនាម/គុណនាមប្រៀបធៀប (comparatif) និង អតិវិសេសគុណនាម/គុណនាមបំផុតភាព (superlatif) : ខ្មៅជាង/សជាង... ខ្មៅយង់/ខ្មៅណាស់ ...។

---

៣៣ : John Lyons, Linguistique générale, Larousse & Jean-Louïs CHISS & alii, Initiation à la problématique structurale , Hachette .

៣៤ : ខ្ញុំសុំ (សុំអនុញ្ញាត) សន្មតថា "បដិ" និង "ប្រតិ" មានន័យខុសគ្នាបន្តិច : មួយសម្គាល់ភាពប្រឆាំងគ្នាមួយទៀតសម្គាល់ចលនាទៅវិញទៅមក ។

(២) - ប្រតិភាពគឺជាភាពដែលសម្គាល់ចលនាពីរទិស : មានទៅមានមក ដូច ÷
"លក់" និង "ទិញ" ឬ "ប្តី" និង "ប្រពន្ធ" :
- ពូ.ក លក់អ្វីអោយពូ.ខ បានសេចក្តីថា ពូ.ខទិញអ្វីនោះពីពូ.ក ។
- ពូ.ក ជាប្តីមីង.ខ បានសេចក្តីថា មីង.ខជាប្រពន្ធពូ.ក ។

(៣) - ក្នុងករណីភាពដៃគូនឹងគ្នា បើមួយណាត្រូវគេបដិសេធ មួយទៀតត្រូវលេចចេញឡើង : ឧ. បើជនណាម្នាក់នៅរស់ គឺគាត់មិនទាន់ស្លាប់ (បើមិនស្លាប់គឺរស់) ។

បដិកម្ម ដូចវេវចនស័ព្ទដែរ តែងទទួលឥទ្ធិពលពីបរិបទ (ទីតាំងក្នុងសម្ព័ន្ធ) :
(១) - un heureux résultat ~ un mauvais résultat ;
(២) - un coup heureux ~ * un coup mauvais (* = ប្រើមិនបាន) ។
("heureux" & "mauvais" ជាបដិស័ព្ទរវាងគ្នាក្នុងឧទាហរណ៍ទី១
តែឈប់មានបដិភាពរវាងគ្នាក្នុងឧទាហរណ៍ទី២) ។

បដិកម្មអាចមានឡើង តាមបដិសេធកម្មសម្ព័ន្ធសាស្ត្រ (négation syntaxique) ឬ តាមបដិសេធកម្មស័ព្ទសាស្ត្រ (négation lexicale) :

- បដិសេធកម្មសម្ព័ន្ធសាស្ត្រ : គាត់មានប្រាជ្ញា ~ គាត់ឥតប្រាជ្ញា
- បដិសេធកម្មស័ព្ទសាស្ត្រ : កុសល ~ អកុសល ។

បដិសេធកម្មសម្ព័ន្ធសាស្ត្រអាចទៅរួចជានិច្ចហើយក៏មានបដិកម្មទៀងទាត់ផងទៀត រីឯបដិសេធកម្មស័ព្ទសាស្ត្រវិញ វាអាចគាំងទៅមិនរួចក្នុងករណីខ្លះ ហើយ ជួនកាលវាក៏អាចមានលទ្ធផលមិនប្រក្រតីផងទៀត :

- chaud ~ *inchaud (* = ឥតមាន) ។
- "différent" & "indifférent" មិនមែនជាបដិស័ព្ទរវាងគ្នាទេ ។
- "propre" មានបដិស័ព្ទ "impropre" & "malpropre" ដែលមានន័យប្លែកគ្នា ។
- "insatiable" <u>ឥតមាន</u> "*satiable" ជាគូបដិបក្ខ<u>ទេ</u> ។

**២.២.៤ -** <u>**អនុស័ព្ទ** (hyponyme) & **មហាស័ព្ទ** (hyperonyme)</u> :

អនុស័ព្ទភាពជាសមមូលជាមួយសញ្ញាណ "អន្តេវេណ/បរិយាបន្នកម្ម"[៣៥] (inclusion) នៃគណិតវិទ្យា។ ក្នុងភាសាបារាំង គុណនាម "écarlate" , "cramoisi" & "vermillon" ជាបែបផ្សេងៗនៃពណ៌ rouge (ក្រហម) គឺជាពណ៌នៅក្នុងពណ៌ rouge : បើគេថាអ្វីមួយ មានពណ៌ écarlate នោះសេចក្តីនេះមានន័យថាអ្វីនោះមានពណ៌ rouge ប៉ុន្តែ បើគេថាអ្វីមួយមានពណ៌ rouge អ្វីនោះមិនប្រាកដជាមានពណ៌ écarlate ទេ ពីព្រោះ ពណ៌ rouge អាចជាពណ៌ écarlate ក៏បានជាពណ៌ cramoisi ក៏បាន និង ជាពណ៌ vermillon ក៏បាន ។

គឺមកពីស្ថានភាពខ្វះប្រតិភាព (réciprocité) បែបនេះហើយបានជាគេថា នេះជាអន្តេវេណឯកទិស (inclusion unilatérale) : "écarlate", "cramoisi" & "vermillon" ជាអនុស័ព្ទរបស់ "rouge" ហើយ "rouge" ជាមហាស័ព្ទសម្រាប់ "écarlate", "cramoisi" & "vermillon" ។

## ៣ - <u>បរិវេណស័ព្ទ-ន័យសាស្ត្រ (champs lexico-sémantiques)</u> :

### ៣.១ - <u>វិចារណកម្មទូទៅ</u> :

ក្នុងវចនវិទ្យា/ស័ព្ទវិទ្យា បរិវេណជាសារព័ននៃធាតុភាសាក្នុងទម្រង់មួយរង្វង់ (un ensemble structurée des éléments linguistiques) ។ មុនដំបូង គប្បីយើងដឹង/ចាំថា ក្នុងវិស័យនេះ គេតែងប្រទះវាក្យស័ព្ទប្លែកៗគ្នាពីសៀវភៅមួយទៅសៀវភៅមួយ ហើយ គប្បីយើងពិនិត្យមើលថា តើបន្លែករវាងវាក្យស័ព្ទនោះជាលទ្ធផលនៃបន្លែករវាងទស្សនៈ ឬ យ៉ាងណា ។

Emile Genouvrier និង Jean Peytard[៣៦] បានបែងចែកបរិវេណជាបរិវេណស័ព្ទសាស្ត្រ (champs lexicaux) និងបរិវេណន័យសាស្ត្រ (champs sémantiques) : បរិវេណស័ព្ទសាស្ត្រ គឺជាសារព័នពាក្យទាំងប៉ុន្មានដែលទាក់ទងជាមួយសញ្ញាណអ្វីណាមួយ ឬ ជាមួយបច្ចេកទេសណាមួយ រីឯបរិវេណន័យសាស្ត្រ វាជាសារព័ននៃការប្រើប្រាស់សម្រាប់ពាក្យណាមួយ ។

---

[៣៥] : ពាក្យ "បរិយាបន្នកម្ម" (inclusion) ត្រូវបានខ្ចីពីសន្ទានុក្រមខេមរយានកម្ម បារាំង-ខ្មែរ , បោះពុម្ពដោយ វិទ្យាស្ថានជាតិខេមរយានកម្ម ឆ្នាំ ១៩៧៣ ។

[៣៦] : cf. Emile Genouvrier & Jean Peytard, Linguistique et enseignement du français, Larousse.

ក្រុម Jean-Louis CHISS[៣៧] មានយោបល់ថា បរិវេណណាក៏ជាបរិវេណន័យ សាស្ត្រដែរ ពីព្រោះ គេសិក្សាពីន័យក្នុងបរិវេណទាំងអស់[៣៨] ។ ភាសាវិទូក្រុមនេះបានចែកបរិវេណជាបរិវេណន័យសាស្ត្របញ្ញត្តិនិយម (champs sémantiques conceptuels) និងបរិវេណន័យសាស្ត្រភាសានិយម (champs sémantiques linguistiques) :

- បរិវេណន័យសាស្ត្របញ្ញត្តិនិយមផ្អែកលើបញ្ញត្តិក្នុងការស្វែងរកន័យ
- បរិវេណន័យសាស្ត្រភាសានិយមផ្អែកលើភាសាក្នុងការស្វែងរកន័យ ។

Jacqueline Picoche[៣៩] បានបញ្ជាក់ថា ការប្រើវិញ្ញត្តិ "បរិវេណសព្ទសាស្ត្រ" និង "បរិវេណន័យសាស្ត្រ" បែបនេះ សម្រាប់សម្គាល់ប្រភេទនៃបរិវេណជាការហួសហេតុពេក ហើយ ពីព្រោះបរិវេណណាក៏ទាក់ទងនឹងន័យក្នុងស័ព្ទដែរ : ការបញ្ជាក់នេះតម្រង់ឆ្ពោះទៅ Emile Genouvrier និង Jean Peytard ដែលបានចែកបរិវេណជាបរិវេណស័ព្ទសាស្ត្រ និងបរិវេណន័យសាស្ត្រ ។ ប៉ុន្តែ គាត់ហាក់ដូចជាចង់បញ្ជាក់ផងដែរថា បរិវេណណាក៏ជាបរិវេណ នៅក្នុងភាសាដែរ : គាត់ហាក់ដូចជាចង់បន្ទោសក្រុម លោក CHISS ដែលបានចែកបរិវេណ ជាបរិវេណន័យសាស្ត្របញ្ញត្តិនិយមនិងបរិវេណន័យសាស្ត្រភាសានិយម ។ ន័យឋិតនៅក្នុងភាសា ហើយ ភាសាតែងតែមានន័យ : ការប្រើវិញ្ញត្តិ "បរិវេណន័យសាស្ត្រភាសានិយម ជាកត្តាធ្វើអោយស្មារតីវិលវល់ ពីព្រោះ វានាំអោយយល់ខុសថា បរិវេណខ្លះអាចឋិតនៅក្រៅភាសា ។

ប៉ុន្តែ ពិតមែនតែមានបន្លែកផ្នែកវាក្យស័ព្ទ (វិញ្ញត្តិ "បរិវេណន័យសាស្ត្រភាសានិយម" ដែលគាត់យល់ថាជាវិញ្ញត្តិមិនត្រឹមត្រូវ) Jacqueline Picoche មានគំនិតស្រដៀងគ្នានឹង គំនិតរបស់ក្រុមលោក J.L.CHISS ដែរ គ្រាន់តែគំនិតរបស់ Jacqueline Picoche មានទ្រង់ទ្រាយច្បាស់លាស់ជាង និងមានវាក្យស័ព្ទត្រឹមត្រូវជាង ។

ភាសាវិទូរូបនេះហៅបរិវេណទាំងអស់ថា "បរិវេណ, ស័ព្ទ-ន័យសាស្ត្រ" (champs lexi-caux sémantiques[៤០]) ដែលគាត់ចែកជាបរិវេណ, ស័ព្ទ-ន័យសាស្ត្ររូបនិយម (champs sémasio-logiques

---

៣៧ : cf. Jean-Louis CHISS & alii, Initiation à la problématique structurale, Hachette 1977 .

៣៨ : ភាសាវិទូក្រុមនេះមិនយល់ស្របនឹងការបែងចែកជាបរិវេណស័ព្ទសាស្ត្រ និង បរិវេណន័យសាស្ត្ររបស់ក្រុម Genouvrier & Peytard ទេ ។

៣៩ : Jacqueline Picoche, Précis de lexicologie française, Nathan 1977, p.68 .

៤០ : គប្បីយើងដូរថា "champs lexico-sémantiques" វិញ ។

ក្រុម Jean-Louis CHISS[៣៧] មានយោបល់ថា បរិវេណណាក៏ជាបរិវេណន័យ សាស្ត្រដែរ ពីព្រោះ គេសិក្សាពីន័យក្នុងបរិវេណទាំងអស់[៣៨] ។ ភាសាវិទូក្រុមនេះបានចែកបរិវេណជាបរិវេណន័យសាស្ត្របញ្ញត្តិនិយម (champs sémantiques conceptuels) និងបរិវេណន័យសាស្ត្រភាសានិយម (champs sémantiques linguistiques) :

- បរិវេណន័យសាស្ត្របញ្ញត្តិនិយមផ្អែកលើបញ្ញត្តិក្នុងការស្វែងរកន័យ
- បរិវេណន័យសាស្ត្រភាសានិយមផ្អែកលើភាសាក្នុងការស្វែងរកន័យ ។

Jacqueline Picoche[៣៩] បានបញ្ជាក់ថា ការប្រើវិញ្ញត្តិ "បរិវេណសព្ទសាស្ត្រ" និង "បរិវេណន័យសាស្ត្រ" បែបនេះ សម្រាប់សម្គាល់ប្រភេទនៃបរិវេណជាការហួសហេតុពេក ហើយ ពីព្រោះបរិវេណណាក៏ទាក់ទងនឹងន័យក្នុងស័ព្ទដែរ : ការបញ្ជាក់នេះតម្រង់ឆ្ពោះទៅ Emile Genouvrier និង Jean Peytard ដែលបានចែកបរិវេណជាបរិវេណស័ព្ទសាស្ត្រ និងបរិវេណន័យសាស្ត្រ ។ ប៉ុន្តែ គាត់ហាក់ដូចជាចង់បញ្ជាក់ផងដែរថា បរិវេណណាក៏ជាបរិវេណ នៅក្នុងភាសាដែរ : គាត់ហាក់ដូចជាចង់បន្ទោសក្រុម លោក CHISS ដែលបានចែកបរិវេណ ជាបរិវេណន័យសាស្ត្របញ្ញត្តិនិយមនិងបរិវេណន័យសាស្ត្រភាសានិយម ។ ន័យឋិតនៅក្នុងភាសា ហើយ ភាសាតែងតែមានន័យ : ការប្រើវិញ្ញត្តិ "បរិវេណន័យសាស្ត្រភាសានិយម ជាកត្តាធ្វើអោយស្មារតីវិលវល់ ពីព្រោះ វានាំអោយយល់ខុសថា បរិវេណខ្លះអាចឋិតនៅក្រៅភាសា ។

ប៉ុន្តែ ពិតមែនតែមានបន្លែកផ្នែកវាក្យស័ព្ទ (វិញ្ញត្តិ "បរិវេណន័យសាស្ត្រភាសានិយម" ដែលគាត់យល់ថាជាវិញ្ញត្តិមិនត្រឹមត្រូវ) Jacqueline Picoche មានគំនិតស្រដៀងគ្នានឹង គំនិតរបស់ក្រុមលោក J.L.CHISS ដែរ គ្រាន់តែគំនិតរបស់ Jacqueline Picoche មានទ្រង់ទ្រាយច្បាស់លាស់ជាង និងមានវាក្យស័ព្ទត្រឹមត្រូវជាង ។

ភាសាវិទូរូបនេះហៅបរិវេណទាំងអស់ថា "បរិវេណ, ស័ព្ទ-ន័យសាស្ត្រ" (champs lexi-caux sémantiques[៤០]) ដែលគាត់ចែកជាបរិវេណ, ស័ព្ទ-ន័យសាស្ត្ររូបនិយម (champs sémasio-logiques

---

[៣៧]: cf. Jean-Louis CHISS & alii, Initiation à la problématique structurale, Hachette 1977 .

[៣៨]: ភាសាវិទូក្រុមនេះមិនយល់ស្របនឹងការបែងចែកជាបរិវេណស័ព្ទសាស្ត្រ និង បរិវេណន័យសាស្ត្ររបស់ក្រុម Genouvrier & Peytard ទេ ។

[៣៩]: Jacqueline Picoche, Précis de lexicologie française, Nathan 1977, p.68 .

[៤០]: គប្បីយើងដូរថា "champs lexico-sémantiques" វិញ ។

ou formels) និង បរិវេណ. ស័ព្ទ-ន័យសាស្ត្របញ្ញត្តិនិយម (champs onomasiologi-ques ou notionnels) :

- បើគេផ្អែកលើមីក្រូ-ប្រព័ន្ធន័យករ ដើម្បីរកន័យបញ្ញត្តិ គេបង្កបរិវេណ.ស័ព្ទ-ន័យសាស្ត្ររូបនិយម ។
- បើគេផ្អែកលើមីក្រូ-ប្រព័ន្ធន័យបញ្ញត្តិ ដើម្បីរកន័យករ គេបង្កបរិវេណ.ស័ព្ទ-ន័យសាស្ត្របញ្ញត្តិនិយម ។

## ៣.២ - សិក្សាលំអិតពីបរិវេណមួយប្រភេទៗ

### ៣.២.១ - បរិវេណ.ស័ព្ទ -ន័យសាស្ត្ររូបនិយម (champs sémasiologiques) :

ដោយផ្អែកលើរូបនៃមូលស័ព្ទ គេបានវិភាគឃើញថា បរិវេណប្រភេទនេះមានលក្ខណៈប្លែកគ្នាជា ៣ក្រុម គឺ :

#### ៣.២.១.១ - បរិវេណជាតិស័ព្ទ (champs étymologiques)

ពីដើមកំណើត ពាក្យទាំងប៉ុន្មានក្នុងបរិវេណជាតិស័ព្ទ (ឬក្នុងជាតិស័ព្ទ តាមលំហៅខ្លី) មានចំណង រូបសាស្ត្រ និង ចំណងន័យសាស្ត្រជាប់ជិតគ្នាឥតគម្លាត ដូច :

- ឧ. ក្នុងភាសាបារាំង : chaîne, chignon, cadenas, concaténation , ... ដែលមានតែជាតិសព្ទទេ ដែលអាចបង្ហាញចំណងរូបសាស្ត្រ និង ន័យសាស្ត្ររវាង ពាក្យទាំងនេះ ;
- ឧ. ក្នុងភាសាខ្មែរ : ដើរ , ផ្ញើរ , គោះ , ឃ្មោះ ,...

ប៉ុន្តែ ក្រោយការឆ្លងកាត់រយៈកាល ចំណងរវាងពាក្យខ្លះក្នុងជាតិស័ព្ទខ្លះត្រូវបានឃ្លាត ពីគ្នា ដោយមានការវិវឌ្ឍ ឬ ពីសំណាក់សូរ ឬ ពីសំណាក់ន័យ ឬ ពីសំណាក់សូរផងនិងពី សំណាក់ន័យផង :

- ឧទាហរណ៍ទាក់ទងនឹងបន្លាស់សូរ :
  - ក្នុងភាសាបារាំង : ami ~ inami > inemi > ennemi ;
  - ក្នុងភាសាខ្មែរ : ទាក់ & ទ្វាក់ ( = អ្នកទាក់ នាមភ្ជាក់ងារកើតឡើងដោយ អន្តរាបទ/-ម-/) > ទ្រមាក់ ( ពាក្យ "ទ្រមាក់" ឃ្លាតចេញពីពាក្យកម្លាយ ដើម "ទ្វាក់" ដែលស្របនឹងយន្តកម្មនៃកម្លាយពាក្យ ក្នុងភាសាខ្មែរ) ។

- ឧទាហរណ៍ទាក់ទងនឹងបន្លាស់ន័យ :

  - ក្នុងភាសាបារាំង : ដោយសារមានការវិវឌ្ឍនៃន័យ ពាក្យ jet, projet, rejet, jeton, jetée, rejeton, sujet, objet, jeter, objecter, interjeter[៤១] ឈប់មានចំណងន័យជាមួយគ្នាហើយ ។

  - ក្នុងភាសាខ្មែរ : ចេញ & ចំណេញ ( ប្រាក់ចំណេញ គឺជាប្រាក់ដែលគេកាត់ចេញពីដើមទុន ឥឡូវនេះ អ្នកខ្លះបានបដិសេធមិនទទួលស្គាល់ចំណងន័យរវាង "ចេញ" និង "ចំណេញ" ) ។

- ឧទាហរណ៍ទាក់ទងនឹងបន្លាស់សូរផង និង បន្លាស់ន័យផង :

  - ក្នុងភាសាបារាំង : គុណនាម ouvrable ចេញពីកិរិយាស័ព្ទ œuvrer ( ពីដើមគេថា "jour œuvrable" ហើយពាក្យ "ouvrable" ជាលទ្ធផលនៃបន្លាស់សូរផង និង នៃបន្លាស់ន័យផង ) ។

  - ក្នុងភាសាខ្មែរ : ពីដើម សទ្ទ & ស័ព្ទ មានរូបនិងន័យដូចគ្នា គឺសម្គាល់សូរសម្លេង ។ ឥឡូវនេះ "សទ្ទ" សម្គាល់សូរ ហើយ "ស័ព្ទ" សម្គាល់ពាក្យដែលមានន័យករផងនិងមានន័យបញ្ញត្តិផង (វិញ្ញត្តិដែលក្នុងនោះ "ស័ព្ទ" មានន័យថាជាសូរ គឺ "ទូរស័ព្ទ" ។

នៅក្នុងភាសាមួយចំនួន ដោយគេប្រើវិធីបង្កើតពាក្យច្រើនប្រភព ( ឬដោយហេតុផ្សេង ទៀត) គេសង្កេតឃើញមានបាតុភូតចម្លែកពីរប្រភេទ គឺ supplétifs[៤២] ដែលយើងអាចប្រែ ថា "ពាក្យជំនួស" និង doublet ដែលយើងអាចប្រែថា "ពាក្យភ្លោះ" ។

- ឧទាហរណ៍ទាក់ទងនឹងពាក្យឥតសន្ទានភាព :

  - ក្នុងភាសាបារាំង : foie & hépatique, jeux & ludique ;
  - ក្នុងភាសាខ្មែរ : ការ/រៀបការ & អាពាហ៍ពិពាហ៍ ។

- ឧទាហរណ៍ទាក់ទងនឹងពាក្យភ្លោះ :

  - ក្នុងភាសាបារាំង : forge & fabrique , charbon & carbone , natal & Noël

---

[៤១] : Exemples empruntés à Jacqueline Picoche, Précis de lexicologie française, Nathan 1977, p 113.

[៤២] : Supplétifs ជាវាក្យស័ព្ទរបស់ Jacqueline Picoche, Précit de lexicologie française, Nathan 1977

- ក្នុងភាសាខ្មែរ : ឋាន & ស្ថាន / ឋិត & ស្ថិត ,...

**៣.២.១.២ -បរិវេណពាក្យកម្លាយ** (champs dérivationnels)

ក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា "La créativité lexicale" លោក Louis Guilbert មិនទទួលស្គាល់ថា មានទំនាក់ទំនងគ្នារវាងបរិវេណពាក្យកម្លាយ និង បរិវេណជាតិស័ព្ទទេ ប៉ុន្តែ ភាសាវិទូភាគច្រើនបានទទួលស្គាល់ថា បរិវេណពាក្យកម្លាយជាអនុប្រព័ន្ធរបស់បរិវេណជាតិស័ព្ទ ឧ. chaîne, chaînon, chaînette, enchaîner, déchaîner, enchaînement ឬ jeune, jeunesse, rajeunir ។

**៣.២.១.៣ - បរិវេណវចនស័ព្ទ** (champs lexémiques)

តាមក្រុមលោក CHISS[៤៣] បរិវេណវចនស័ព្ទគឺជាលទ្ធភាពក្នុងការប្រើប្រាស់វចនស័ព្ទណាមួយក្នុងបរិបទមួយចំនួន ដែលអាចទទួលយកវចនស័ព្ទនោះបាន : គេផ្អែកលើការប្រើប្រាស់វចនស័ព្ទនោះ ដើម្បីសម្គាល់វង្វង់ន័យរបស់វា។ សម្រាប់ភាសាបារាំងវចនានុក្រម D.F.C. និង វចនានុក្រម Robert Méthodique ជាជំនួយយ៉ាងធំដល់សាធារណជនក្នុងការប្រើប្រាស់ពាក្យអោយស្របតាមទម្លាប់ទូទៅ (វចនានុក្រម Larousse ផ្តល់ត្រឹមតែន័យ មិនសូវពន្យល់ពីការ ប្រើប្រាស់ពាក្យទេ) ។

**៣.២.២ - បរិវេណ.ស័ព្ទ -ន័យសាស្ត្របញ្ញត្តិនិយម** (champs onomasiologiques):

**៣.២.២.១ - បរិវេណអតិបូរណន័យតា** (champs archi-séméniques):

ចំពោះបរិវេណប្រភេទនេះ គេផ្អែកលើសន្ទានន័យដើម្បីភ្ជាប់ពាក្យជាមីក្រូ-ប្រព័ន្ធ (ពីន័យរបស់ពាក្យទៅរូបរបស់ពាក្យ) ។ អតិបូរណន័យតា គឺជាន័យតាដែលជាលទ្ធផលនៃអព្យាក្រឹតនីយកម្មក្នុងមីក្រូ-ប្រព័ន្ធណាមួយ (សូមអានភាគខាងដើមទាក់ទងនឹងអតិបូរណន័យតា): អតិ-បូរណន័យតា (archisémème) ជាចំណុះន័យរបស់អតិ-វចនស័ព្ទ (archilexème) ដែលមានន័យករផងនិងន័យបញ្ញត្តិផង។ ពិតមែនតែគេចេញដំណើរពីអតិ-បូរណន័យតា (គេយកន័យធ្វើជាខ្សែគំនិត) តែនៅទីបញ្ចប់គេយកអតិ-វចនស័ព្ទមកពិនិត្យ (ពីព្រោះ បញ្ញត្តិរបស់ ពាក្យនឹងមានអត្ថិភាពក៏ដោយសារតែរូបរបស់ពាក្យដែរ) ដូចតទៅ :

- ឧទាហរណ៍ក្នុងភាសាបារាំង : une chauffeuse (កៅអីទាប) € (នៅ

---

[៤៣]: Op. cit., J.L. CHISS & alii , Iniation à la problématique structurale .

ក្នុងក្រុម) chaise ϵ siège ϵ meuble ϵ objet fabriqué ϵ chose[៤៤]

- ឧទាហរណ៍ក្នុងភាសាខ្មែរ : កៅអី ϵ អាសនៈ ϵ គ្រឿងសង្ហារឹម ϵ របស់មនុស្សធ្វើ ϵ វត្ថុ។

### ៣.២.២.២ - បរិវេណសមាគតភាព (champs associatifs):

គប្បីយើងចាំថា បរិវេណសមាគតភាពជាបរិវេណបញ្ញត្តិនិយម។ ផ្ទុយពីបរិវេណនៃចំនុច ២.២.១ ដែលជាបរិវេណរូបនិយម (រូបពាក្យ) ករណីលើកនេះផ្អែកលើបញ្ញត្តិ (ឬន័យ) របស់ពាក្យ ដើម្បីចងពាក្យជាមីក្រូ-ប្រព័ន្ធ។ គឺដោយសារសមាគតកម្ម[៤៥] បានជា "ឡាន"[៤៦] ធ្វើអោយយើងគិតទៅដល់ម៉ាកឡាន (Toyota, Hyundai, peugeot,...) ទៅដល់ផ្នែកនានាក្នុងឡាន (កង់, ចង្កូត, ម៉ាស៊ីន,...) ទៅដល់កន្លែងទាក់ទងនឹងឡាន (យានដ្ឋាន, ចំណតឡាន, បេនឡាន, ហាងសាំង,...) ទៅដល់ទង្វើទាក់ទងនឹងឡាន (បើកបរ, ចាក់សាំង, ជួសជុល ,...), - ល- ។

### ៣.២.៣ - បរិវេណល្បាយ (champs mixtes):

ការបែងចែកបរិវេណជាពីរប្រភេទដាច់គ្នា គ្រាន់តែជាការចាំបាច់ខាងផ្លូវវិធីសាស្ត្រ ដើម្បីអោយងាយយល់ ប៉ុន្តែ តាមជាក់ស្តែងបរិវេណទាំងពីរតែងតែប្រទាក់ក្រឡាលាយឡំជាបរិវេណល្បាយ ដូចមានឧទាហរណ៍ក្នុងភាសាបារាំង[៤៧] ខាងក្រោមនេះ :

Peur > avoir peur > apeurer > peureux > peureusement ;

↓

inquiétude > s'inquiéter > inquiéter > inquiet ;

↓

etc ,...

<u>វិភាគ</u> :

- ពីលើចុះក្រោម : បរិវេណ.ស័ព្ទ-ន័យសាស្ត្របញ្ញត្តិនិយម (champs onomasiologiques) ពីព្រោះ គេផ្អែកលើន័យដើម្បីប្រមូលផ្តុំពាក្យ peur និងពាក្យ inquiétude ។

---

[៤៤]: ឧទាហរណ៍ខ្ចីពី Jacqueline Picoche, Précis de lexicologie française (ouvrage déjà cité), p. 97.

[៤៥]: សមាគតកម្ម គឺជាការភ្ជាប់គំនិតមួយទៅគំនិតមួយទៀត ដោយគំនិតទាំងពីរមានចំណងជាប់គ្នាតាមរយៈន័យឬតាមរយៈជំនិត (ជំនិតក្នុងលំហ/ក្នុងពេលវេលា/ក្នុងសកម្មភាព ,...) ។

[៤៦]: ឧទាហរណ៍ទាំងនេះត្រូវបានខ្ចីមកពី Roland Eluerd, Pour aborder la linguistique, Edition ESF 1979, p.138 .

[៤៧]: Op. cit., Jacqueline Picoche, Précis de lexicologie française, p.128 .

- ពីឆ្វេងទៅស្តាំ : បរិវេណ.ស័ព្ទ-ន័យសាស្ត្ររូបនិយម (champs sémasiologiques) ពីព្រោះ គេផ្អែកលើរូបពាក្យ peur ដើម្បីប្រមូលផ្តុំពាក្យទាំងប៉ុន្មានដែលមានពាក្យ peur នេះជាឫសរួម ។
- ដូច្នេះហើយ បរិវេណ ដែលគេចាប់បាន ហើយ ដែលគេតម្រៀបជាបណ្តាញខាងលើនេះ គឺជាបរិវេណល្បាយ ។

# គន្ថនិទ្ទេស


- BAYLON Christian & FABRE Paul , La sémantique , Nathan 1978 ;
- CHOMSKY Noam , Questions de sémantique, Editions du Seuil 1975 ;
- DUBOIS Jean & Claude , Introduction à la lexicographie: le dictionnaire, Larousse 1971 ;
- GALISSON Robert , Lexicologie et enseignement des langues, Hachette 1979 ;
  --------- L'apprentissage systématique du vocabulaire, Hachette/Larousse 1970 ;
- GREIMAS A. J. , Sémantique structurale, Larousse 1966 ;
- GUILBERT Louis , La créativité lexicale, Larousse 1975 ;
- GLATIGNY Michel & COLLIGNON Lucien , Les dictionnaires. Initiation à la lexicographie, Editions CEDIC 1978 ;
- GUIRAUD Pierre , Les mots étrangers, P. U. F, (Que sais-je ? ) 1965 ;
  ---------- L'étymologie, P. U. F. (Que sais-je ? ) 1964 ;
- MAROUZEAU J. , Précis de stylistique française, Masson et Cie 1950 ;
- MICHEA R., SAUVAGEOT A., RIVENC P., GOUGENHEIM G., L'élaboration du français fondamental (1er degré), Didier 1967 ;
- PICOCHE Jacqueline , Précis de lexicologie française, Nathan 1977 ;
  ---------- Structures sémantiques du lexique français , Nathan 1986 ;
- REY Alain , La lexicologie, Klincksieck 1970 ;
- TUTESCU Mariana , Précis de sémantique française, Klincksieck 1975 .

## បញ្ជីពាក្យបច្ចេកទេស ដែលមាន ក្នុងសិក្សាកថានេះ

### ខ្មែរ -បារាំង

១- កន្សោមពាក្យកាត់ : sigle

២- កន្សោមល្បួត : groupe figé

៣- កម្មរងវត្ថុសភាព : transitivité

៤- គណនីយភាព : nombrabilité

៥- ជាតិសព្ទ : étymologie

៦- ជីវិតភាព : animé

៧- ជំនឿន : progression

៨- ឋាននូវន័យតា : sème classificateur / classème

៩- តម្រាប់សូរ : onomatopée

១០- តេស្តដែក : test de séparabilité / d'insertion

១១- តេស្ត(តំណាក់)កត្តារួម : test de mise en facteur commun

១២- តេស្តកំណាត់ : test de répétition partielle

១៣- តេស្តតំណួរ : test de commutation

១៤- ទម្រសូរ : support acoustique

១៥- ទ្រឹស្តីពន្យារកម្ម : théorie de la médiation

១៦- ន័យ : sens

១៧- ន័យករ : signifiant

១៨- ន័យកម្ម : signification

១៩- ន័យកម្មវិទ្យា : sémiologie

២០- ន័យកម្មវិស័យ : dénotation

២១- ន័យតា : sème / component

២២- ន័យបញ្ញត្តិ : signifié

២៣- ន័យបរិវាទ/បរិបទ : sens contextuel

២៤- ន័យពាំត្រណោត : sens ambigu / ambiguité

២៥- ន័យពាំត្រណោតស័ព្ទសាស្ត្រ : ambiguité lexicale

២៦- ន័យវិទ្យា : sémantique

២៧- ន័យអញ្ញថា : connotation

២៨- បដិកម្ម : opposition

២៩- បដិស័ព្ទ : antonyme

៣០- បដិសេធកម្មស័ព្ទសាស្ត្រ : négation lexicale

៣១- បដិសេធកម្មសម្ព័ន្ធសាស្ត្រ : négation syntaxique

៣២- បណ្តាស័ព្ទ : allomorphes

៣៣- បរិព័ន្ធ/បរះឃ្លា : périphrase

៣៤-បរិវេណកម្លាយភាព : champs dérivationnels

៣៥- បរិវេណជាតិស័ព្ទ : champs étymologiques

៣៦- បរិវេណន័យសាស្ត្រ : champs sémantiques

៣៧- បរិវេណន័យសាស្ត្របញ្ញត្តិនិយម :
champs sémantiques conceptuels

៣៨- បរិវេណន័យសាស្ត្រភាសានិយម : champs sémantiques
linguistiques

៣៩- បរិវេណវចនស័ព្ទ : champs lexémiques

៤០- បរិវេណល្បាយ : champs mixtes

៤១- បរិវេណសមាគតភាព : champs associatifs

៤២- បរិវេណ.ស័ព្ទ-ន័យសាស្ត្រ : champs lexico-
sémantiques

៤៣- បរិវេណ.ស័ព្ទ-ន័យសាស្ត្ររូបនិយម : champs
sémasiologiques

៤៤- បរិវេណ.ស័ព្ទ-ន័យសាស្ត្របញ្ញត្តិនិយម :
champs onomasiologiques ou notionnels

៤៥- បរិវេណបញ្ញត្តិនិយម : champs notionels

៤៦- បរិវេណរូបនិយម : champs formels

៤៧- បរិវេណស័ព្ទសាស្ត្រ : champs lexicaux

៤៨- បរិវេណអតិបូរណន័យតា : champs archi-séméniques

៤៩- បូរណន័យតា : sémème

៥០- បូរណស័ព្ទ : lexie

៥១- ប្រតិភាព : réciprocité

៥២- ពាក្យជន្លង : supplétif

៥៣- ពាក្យបង្គោល : complété

៥៤- ពាក្យភ្លោះ : doublet

៥៥- ពាក្យរណប : complétif

៥៦- ពិភពវាចា : univers de rhétorique

៥៧- មាត្រដ្ឋាន : échelle

៥៨- មហាស័ព្ទ : hyperonyme

៥៩- មីក្រូ-បរិវេណ.ស័ព្ទ-ន័យសាស្ត្រ : micro-champs lexico-sémantiques

៦០- មីក្រូ-ប្រព័ន្ធស័ព្ទសាស្ត្រ : micro-systèmes lexicaux

៦១- មូលស័ព្ទ : monème

៦២- យោងប៉ោង : référence

៦៣- រូបសូរ : image acoustique

៦៤- រូបស័ព្ទ : morphème

៦៥- រូបស័ព្ទវិទ្យា : morphologie (វិជ្ជា)

៦៦- រូបសាស្ត្រ : morphologie ( រូបពាក្យ)

៦៧- ល្អូត : figé

៦៨- វចនវិទ្យា/ស័ព្ទវិទ្យា : lexicologie

៦៩- វចនស័ព្ទ : lexème

៧០- វចនាលេខនី : lexicographie

៧១- វចនាលេខវិទូ : lexicographe

៧២- វាក្យស័ព្ទវិទ្យា : "lexistique"

៧៣- វាចាវិលាស : locution

៧៤- វិញ្ញត្តិ : expression

៧៥- វិធីរូប-ស័ទ្ទតានិយម : procédés morpho-
phonologiques

៧៦- វិភត្តិនីយកម្ម : conjugaison / déclinaison

៧៧- វិភាគន័យតា : analyse sémique / componentielle

៧៨- វិសាលស័ព្ទ : euphémisme

៧៩- វេវចនស័ព្ទ : synonyme

៨០- សញ្ញាណ : notion

៨១- សញ្ញាវិទ្យា : sémiotique

៨២- សញ្ញាតា : trait

៨៣- សញ្ញាតាបន្លឺសូរ : trait articulatoire

៨៤- សញ្ញាតាបរិវាទ/បរិបទ : trait contextuel

៨៥- សទិសលេខនី : homographe

៨៦- សទិសស័ព្ទ : homonyme

៨៧- សទិសសូរ : homophone

៨៨- ស័ទ្ទតា : phonème

៨៩- ស័ទ្ទតាវិទ្យា : phonologie / phonématique

៩០-សន្ទស្សន៍ : indice

៩១- សន្ធិយោគ : articulation

៩២- សន្ធិយោគពីរជាន់ : double articulation

៩៣- សម្ព័ន្ធ/សម្ព័ន្ធវិទ្យា : syntaxe

៩៤- សមាគតកម្ម : association ( ក្នុងន័យថា "ការគួបផ្សំគ្នា")

៩៥- សម្ដីបង្អើប : litote

៩៦- សារព័ន : ensemble

៩៧- សូរ : son

៩៨- សូរស័ព្ទភាសា : signe linguistique

៩៩- អត្តន័យតា : sème identificateur / sui-sème

១០០- អតិបូរណន័យតា : archi-sémème

១០១- អតិវចនស័ព្ទ : archi-lexème

១០២- អតិស័ទ្ទតា : archi-phonème

១០៣- អនុស័ព្ទ : hyponyme

១០៤- អន្តរកម្ម : intersection

១០៥- អន្តេវេណ : inclusion

១០៦- អន្តេវេណឯកទិស : inclusion unilatérale

១០៧- អង្គតា : voi

១០៨- អព្យាក្រឹតកម្ម : neutralisation

១០៩- អ័ក្សរយៈកាល : axe diachronique

១១០- អាជ្ញាភាព : arbitraire

១១១- ឯកតា : unité

១១២- ឯកតាក្នុងន័យ : unité de sens

-----

**បារាំង -ខ្មែរ**

1- allomorphes : បណ្តាស័ព្ទ

2- ambiguité lexicale : ន័យពាំត្រណោតស័ព្ទសាស្ត្រ

3- analyse sémique / componentielle : វិភាគន័យតា

4- animé : ជីវិតភាព

5- antonyme : បដិស័ព្ទ

6- arbitraire : អាជ្ញាភាព

7- archi-lexème : អតិវចនស័ព្ទ

8- archi-phonème : អតិសទ្ទតា

9- archi-sémème : អតិបូរណន័យតា

10- articulation : សន្ធិយោគ

11- association ( ក្នុងន័យថា "ការគួបផ្សំគ្នា" ) : សមាគតកម្ម

12- axe diachronique : អ័ក្សរយៈកាល

13- champs archi-séméniques : បរិវេណអតិបូរណន័យតា

14- champs associatifs : បរិវេណសមាគតភាព

15- champs dérivationnels : បរិវេណកម្លាយភាព

16- champs étymologiques : បរិវេណជាតិស័ព្ទ

17- champs formels : បរិវេណរូបនិយម

18- champs lexémiques : បរិវេណវចនស័ព្ទ

19- champs lexicaux : បរិវេណស័ព្ទសាស្ត្រ

20- champs lexico- sémantiques : បរិវេណ.ស័ព្ទ-ន័យសាស្ត្រ

21- champs mixtes : បរិវេណល្បាយ

22- champs notionels : បរិវេណបញ្ញត្តិនិយម

23- champs onomasiologiques ou notionnels : បរិវេណ.
ស័ព្ទន័យសាស្ត្រ បញ្ញត្តិនិយម

24- champs sémantiques : បរិវេណន័យសាស្ត្រ

25- champs sémantiques conceptuels : បរិវេណន័យសាស្ត្របញ្ញត្តិនិយម

26- champs sémantiques linguistiques : បរិវេណន័យសាស្ត្រភាសានិយម

27- champs sémasiologiques : បរិវេណ.
ស័ព្ទ-ន័យសាស្ត្ររូបនិយម

28- complété : ពាក្យបង្គោល

29- complétif : ពាក្យរណប

30- conjugaison / déclinaison : វិភត្តិនីយកម្ម

31- connotation : ន័យអញ្ញថា

32- dénotation : ន័យកម្មវិស័យ

33- double articulation : សន្ធិយោគពីរជាន់

34- doublet : ពាក្យភ្លោះ

35- échelle : មាត្រដ្ឋាន

36- ensemble : សារព័ន

37- étymologie : ជាតិសព្ទ

38- euphémisme : វិសាលស័ព្ទ

39- expression : វិញ្ញត្តិ

40- figé : ល្មួត

41- groupe figé : កន្សោមល្មួត

42- homographe : សទិសលេខនី

43- homonyme : សទិសស័ព្ទ

44- homophone : សទិសសូរ

45- hyperonyme : មហាស័ព្ទ

46- hyponyme : អនុស័ព្ទ

47- image acoustique : រូបសូរ

48- inclusion : អន្តេវេណ

49- inclusion unilatérale : អន្តេវេណឯកទិស

50- indice : សន្ទស្សនី

51- intersection : អន្តរកម្ម

52- lexème : វចនស័ព្ទ

53- lexicographe : វចនាលេខវិទូ

54- lexicographie : វចនាលេខនី

55- lexicologie : វចនវិទ្យា/ស័ព្ទវិទ្យា

56- lexie : បូរណស័ព្ទ

57- lexistique : វាក្យស័ព្ទវិទ្យា

58- litote : សម្ដីបង្អើប

59- locution : វាចាវិលាស

60- micro-champs lexico-sémantiques : មីក្រូ-បរិវេណ. ស័ព្ទន័យសាស្ត្រ

61- micro-systèmes lexicaux : មីក្រូ-ប្រព័ន្ធស័ព្ទសាស្ត្រ

62- monème : មូលស័ព្ទ

63- morphème : រូបស័ព្ទ

64- morphologie ( រូបពាក្យ) : រូបសាស្ត្រ

65- morphologie (វិជ្ជា) : រូបស័ព្ទវិទ្យា

66- négation lexicale : បដិសេធកម្មស័ព្ទសាស្ត្រ

67- négation syntaxique : បដិសេធកម្មសម្ព័ន្ធសាស្ត្រ

68- neutralisation : អព្យាក្រឹតកម្ម

69- nombrabilité : គណនីយភាព

70- notion : សញ្ញាណ

71- onomatopée : តម្រាប់សូរ

72- opposition : បដិកម្ម

73- périphrase : បរិព័ន្ធ/បរៈឃ្លា

74- phonème : ស័ទ្ទតា

75- phonologie / phonématique : ស័ទ្ទតាវិទ្យា

76- procédés morpho-phonologiques : វិធីរូប-ស័ទ្ទតានិយម

77- progression : ជំនឿន

78- réciprocité : ប្រតិភាព

79- référence : យោបោង

80- sémantique : ន័យវិទ្យា

81- sème / component : ន័យតា

82- sème classificateur / classème : ឋានន្តរន័យតា

83- sème identificateur / sui-sème : អត្តន័យតា

84- sémème : បូរណន័យតា

85- sémiologie : ន័យកម្មវិទ្យា

86- sémiotique : សញ្ញាវិទ្យា

87- sens : ន័យ

88- sens ambigu / ambiguité : ន័យពាំត្រណោត

89- sens contextuel : ន័យបរិវាទ/បរិបទ

90- sigle : កន្សោមពាក្យកាត់

91- signe linguistique : សូរស័ព្ទភាសា

92- signifiant : ន័យករ

93- signification : ន័យកម្ម

94- signifié : ន័យបញ្ញត្តិ

95- son : សូរ

96- supplétif : ពាក្យជំនួស

97- support acoustique : ទម្រសូរ

98- synonyme : វេវចនស័ព្ទ

99- syntaxe : សម្ព័ន្ធ/សម្ព័ន្ធវិទ្យា

100- test de commutation : តេស្តតំណូរ

101- test de mise en facteur commun : តេស្តតំណាក់កត្តារួម

102- test de répétition partielle : តេស្តកំណាត់

103- test de séparabilité / d'insertion : តេស្តជែក

104- théorie de la médiation : ទ្រឹស្តីពន្យារកម្ម

105- trait : សញ្ញាតា

106- trait articulatoire : សញ្ញាតាបន្លឺសូរ

107- trait contextuel : សញ្ញាតាបរិវាទ/បរិបទ

108- transitivité : កម្មរងវត្ថុសភាព

109- unité : ឯកតា

110- unité de sens : ឯកតាក្នុងន័យ

111- univers de rhétorique : ពិភពវាចា

# មាតិកា

## សញ្ញាណទូទៅ :

**I- សញ្ញាណទូទៅលើបញ្ញត្តិមូលដ្ឋាន :**


១- សូរស័ព្ទភាសា ឬ សូរស័ព្ទ (singne linguistique) ................................. ទំព័រ ១

១.១- អ្វីហៅថា "សូរស័ព្ទភាសា" ? ..........................................................--- ១

១.២- លក្ខណៈនៃសូរស័ព្ទភាសា ..........................................................--- ៤

១.៣- ប្រភេទន័យនៃសូរស័ព្ទភាសា ......................................................--- ៥

១.៣.១- ន័យកម្ម (signification) ......................................................--- ៥

១.៣.២- ន័យ (sens) ..........................................................................--- ៦

១.៣.៣- យោបោង (référence) ................................................................--- ៦

១.៣.៤- ន័យ.កម្មវិស័យ (dénotation) & ន័យអញ្ញថា (connotation) ........--- ៧

១.៤- ព្រំដែន : តើសូរស័ព្ទភាសានៅត្រង់ណា ?...............................................--- ៧

២- ពាក្យ (mot) .............................................................................--- ៨

៣- មូលស័ព្ទ (monème) & ស័ទ្ទតា (phonème) .................................--- ៨

៣.១- មូលស័ព្ទ ..................................................................................--- ៨

៣.២- ស័ទ្ទតា ....................................................................................--- ១០

៤- វិចនស័ព្ទ (lexème) ...................................................................--- ១១

៥- រូបស័ព្ទ (morphème) & បណ្តាស័ព្ទ (allomorphes) .......................--- ១១

៦- បូរណាស័ព្ទ (lexie) .....................................................................--- ១៣

៧- ការអនុវត្តតេស្តរកពាក្យសមាសបារាំង និង ការអនុវត្ត
បណ្តោះអាសន្នរកពាក្យសមាសខ្មែរ : ..................................................--- ១៥

៧.១- ការអនុវត្ត លើ កន្សោមពាក្យបារាំង ...................................................--- ១៥

៧.១.១- តេស្តដែក (test de séparabilité/d'insertion) .......................--- ១៥

៧.១.២- តេស្ត (តំណាក់) កត្តារួម (test de mise en facteur commun) .--- ១៥

៧.១.៣- តេស្តកំណាត់ (test de répétition partielle) ...........................--- ១៥

៧.១.៤- តេស្តតំណូរ (test de commutation) ........................................--- ១៦

៧.២- ការអនុវត្ត លើ កន្សោមពាក្យខ្មែរ ....................................................--- ១៦

៧.២.១- តេស្តជែក ..................................................................................--- ១៦

៧.២.២- តេស្ត (តំណាក់) កត្តារួម ..........................................................--- ១៧

៧.២.៣- តេស្តកំណាត់ ........................................................................--- ១៨

៧.២.៤- តេស្តតំណូរ ..............................................................................--- ១៨

**II- សញ្ញាណទូទៅលើវិជ្ជាសន្តាន/វិជ្ជាជិតខាងគ្នា :**

១- ប្រវត្តិនៃបញ្ញត្តិមួយចំនួន និង វិជ្ជាពាក់ព័ន្ធ : ន័យកម្មវិទ្យា (sémiologie),
សញ្ញាវិទ្យា (sémiotique), និង ន័យវិទ្យា (sémantique) ................--- ១៩

២- រូបស័ព្ទវិទ្យា (morphologie) .........................................................--- ២០

៣- វចនវិទ្យា/ស័ព្ទវិទ្យា (lexicologie) ..................................................--- ២០

៤- វាក្យស័ព្ទវិទ្យា ("lexistique") .........................................................--- ២១

៥- វចនាលេខនី (lexicographie) .......................................................--- ២១

## គោលសំខាន់ៗ នៃ ន័យកម្មវិទ្យា :

១- ឯកតាក្នុងន័យ (unité de sens) .......................................................--- ២២

១.១- ន័យតា (sème/component) និងវិភាគន័យតា
(analyse sémique/componentielle) ..................................--- ២២

១.២- អត្តន័យតា (sème identificateur/sui-sème) និង
ឋានន្តរន័យតា ( sème classificateur/classème) ......................--- ២៤

១.២.១- អត្តន័យតា (sui-sème)..........................................................--- ២៤

១.២.២-ឋានន្តរន័យតា (classème) ......................................................--- ២៥

១.៣- បូរណន័យតា (sémème) ..........................................................--- ២៥

១.៤- អតិបូរណន័យតា (archi-sémème) ............................................--- ២៦

១.៥- អតិវចនស័ព្ទ (archi-lexème) .....................................................--- ២៧

២- ទំនាក់ទំនងរវាងន័យ (Relations sémantiques) ...............................--- ២៧

២.១- វិចារណកម្មទូទៅ .......................................................................--- ២៧

២.២- សិក្សាលំអិតអំពីប្រភេទនីមួយៗនៃទំនាក់ទំនងរវាងន័យ ...........................--- ២៩

២.២.១- សទិសស័ព្ទ និង ពហុន័យ (homonyme & polysens) ..................--- ២៩

២.២.១.១- សទិសស័ព្ទ ...............................................................................--- ២៩

២.២.១.២- ពហុន័យ ......................................................................................--- ៣១

២.២.២- វេវចនស័ព្ទ (synonyme) ........................................................--- ៣១

២.២.៣- បដិស័ព្ទ (antonyme) ............................................................--- ៣២

២.២.៤- អនុស័ព្ទ (hyponyme) & មហាស័ព្ទ (hyperonyme) ................--- ៣៤

៣- បរិវេណ.ស័ព្ទ-ន័យសាស្ត្រ (champs lexico-sémantiques) .............--- ៣៤

៣.១- វិចារណកម្មទូទៅ .........................................................................--- ៣៤

៣.២- សិក្សាលំអិតពីបរិវេណមួយប្រភេទៗ ..................................................--- ៣៦

៣.២.១- បរិវេណ.ស័ព្ទ-ន័យសាស្ត្ររូបនិយម
(champs sémasiologiques) ..........................................--- ៣៦

៣.២.១.១- បរិវេណជាតិស័ព្ទ (champs étymologiques) .......................--- ៣៦

៣.២.១.២- បរិវេណពាក្យកម្លាយ (champs dérivationnels)..................--- ៣៧

៣.២.១.៣- បរិវេណវចនស័ព្ទ (champs lexémiques) ...........................--- ៣៨

៣.២.២- បរិវេណ.ស័ព្ទ-ន័យសាស្ត្របញ្ញត្តិនិយម
(champs onomasiologiques) .........................................--- ៣៨

៣.២.២.១- បរិវេណអតិ-បូរណន័យតា (champs archi-séméniques)......--- ៣៨

៣.២.២.២- បរិវេណសមាគតភាព (champs associatifs) .......................--- ៣៩

៣.២.៣- បរិវេណល្បាយ (champs mixtes) .........................................--- ៣៩

**គន្ថនិទ្ទេស** ..........................................................................--- ៤១

**បញ្ជីពាក្យបច្ចេកទេស ដែលមាន ក្នុងសិក្សាកថានេះ** .............................--- ៤២